NGO Committee

# គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បីតាមដាននូវ
# សូចនាកររបស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា

NGO Committee for the Monitoring of CDCF Indicators

ភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៧

## សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលស្តីពី
## ការតាមដានសូចនាកររបស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា

### មាតិការ


សេចក្តីសង្ខេប ........................................................2
ការតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ................................3
សុខាភិបាល ........................................................5
វិស័យកសិកម្ម និងទឹក ....................................................7
កំណែទម្រង់ដីធ្លី........................................................9
កំណែទម្រង់ព្រៃឈើ.................................................... 13
វិស័យជលផល .................................................... 16
ប្រព័ន្ធច្បាប់ និងតុលាការ ............................................. 20
ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ................................. 23
វិមជ្ឈការ និង វិសហមជ្ឈការ ......................................... 28
ថវិកាជាតិ និង ហិរញ្ញវត្ថុសាធារណៈ..................................... 31

# សេចក្តីសង្ខេប

អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍ចំពោះកិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល-ម្ចាស់ជំនួយ (GDCC) ដែលបានប្រព្រឹត្តទៅនាសប្តាហ៍នេះថាជាឱកាសដ៏ល្អមួយសម្រាប់តាមដានមើលវឌ្ឍនភាពលើសូចនាករតាមដានរួម (JMIs) ដែលបានឯកភាពគ្នានៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) កាលពីខែមិថុនា។ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានជំហានជាវិជ្ជមានមួយចំនួននៅក្នុងរយៈពេលមួយត្រីមាសកន្លងមកនេះឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅនានា ជាពិសេសតាមរយៈការអនុម័តផែនការយុទ្ធសាស្ត្រសម្រាប់ក្រសួងផែនការ និង ការរៀបចំសេចក្តីព្រាងឯកសារគោលនយោបាយមួយស្តីពីសេរីភាពនៃពតិមាន។ ប៉ុន្តែដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ខាងក្រោមបង្ហាញថា ត្រីមាសទីមួយនៃការពិនិត្យតាមដានលើសូចនាករតាមដានរួម (JMIs) ដែលទើបបានជ្រើសរើសនាពេលថ្មីៗនេះបានបង្ហាញពីលទ្ធផលមានកម្រិត នៅឡើយមកដល់ពេលនេះ ហើយយើងសង្ឃឹមថាវឌ្ឍនភាពធំៗនឹងត្រូវបានរាយការណ៍នៅដំណាច់ត្រីមាសទីពីរ។

នៅក្នុងកិច្ចប្រជុំ GDCC ដែលជាកិច្ចប្រជុំទីមួយចាប់តាំងពីក្រោយកិច្ចប្រជុំ CDCF កាលពីខែ មិថុនាកន្លងទៅអង្គការមិនមែនរដ្ឋាភិបាលសូមបញ្ជាក់ឡើងវិញនូវសារសំខាន់នៃដំណើរការនេះថាជាឱកាសមួយសម្រាប់ឱ្យក្រុមសង្គមស៊ីវិលធ្វើការពិនិត្យតាមដានវឌ្ឍនភាពដែលចាំបាច់សម្រាប់កិច្ចអភិឌ្ឍន៍កម្ពុជា។ ទោះជាយ៉ាងណាក្តី យើងខ្ញុំសូមកត់សម្គាល់ថា JMIs មួយចំនួនត្រូវបានដកចេញពីអាទិភាពនៃឆ្នាំកន្លងមកដែលគឺជាប្រការគួរឱ្យស្តាយដោយសារ JMIs ទាំងនោះត្រូវបានចាត់ទុកជាបញ្ហាអាទិភាពកាលពីពេលមុន។ សូមមើលឧបសម្ព័ន្ធនៃសេចក្តីថ្លែងការណ៍នេះដើម្បីមើលការវិភាគពេញលេញលើ JMIs ដែលទើបបានជ្រើសរើសសម្រាប់ឆ្នាំ២០០៧។ ទោះបីជាអង្គការក្រៅរដ្ឋាភិបាលវាយតម្លៃខ្ពស់ចំពោះលក្ខណៈវិនិច្ឆ័យថ្មីសម្រាប់ជ្រើសរើស JMIs ក្តីក៏អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវដល់រាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍សូមឱ្យធានាឱ្យបានថាវឌ្ឍនភាពដែលសម្រេចបានលើ JMIs អាចវាស់បានដោយគ្មានលំអៀងតាមរយៈការកំណត់កាលវិភាគសកម្មភាពទាំងឡាយដែលកំណត់ដោយ JMI នីមួយៗ។

# ការតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

## i) សូចនាករតាមដានរួម

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវ |
|---|---|---|
| ១- អនុម័តផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ (MPSP) | ១. អនុម័តសេចក្តីព្រាងបញ្ចប់ផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ ។ នេះគឺជាឯកសារយុទ្ធសាស្ត្រសម្រាប់អនុវត្ត ដោយមានការសម្រប សម្រួលពី ដៃគូអភិវឌ្ឍន៍នេះ ។<br>២. ច្របាច់បញ្ចូលគ្នានូវរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផ្នែក ឪការតម្រឹមឪ នៃរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការរបស់ ក.អ.ក/គ.ជ.នា ឱ្យទៅជារបាយការណ៍វិភាគតែមួយ ដែលបញ្ជាក់ពីវឌ្ឍនភាពស្តីពីការអនុវត្តន៍សូចនាករសំខាន់ៗ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការតម្រឹមធនធាន ដែលបានសន្យាជាមួយនឹងអាទិភាព នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ | ក្រសួងផែនការ<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

## ii) វឌ្ឍនភាពដែលបានតាមដាន

### សូចនាករ ១.១: អនុម័តផែនការ យុទ្ធសាស្ត្ររបស់ក្រសួងផែនការ (MPSP)

អង្គការមិនមែនរដ្ឋាភិបាល សូមស្វាគមន៍ចំពោះកិច្ចខំប្រឹងប្រែងរបស់ក្រសួងផែនការក្នុងរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រសួងដែលទើបបានអុនម័តកាលពីខែកក្កដាកន្លងទៅនេះ ។ ក៏ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាលសូមស្នើអោយមានការបើកទូលាយក្នុងការពិគ្រោះយោបល់ជាមួយសមាជិករបស់ក្រុមការងារបច្ចេកទេសស្តីពីការធ្វើផែនការនិងការកាត់បន្ថយភាពក្រីក្រទៅលើផែនការយុទ្ធសាស្ត្រនេះ ។ ជាងនេះទៅទៀតអង្គការមិនមែនរដ្ឋាភិបាលសូមស្នើអោយដៃគូអភិវឌ្ឍន៍គាំទ្ររួមគ្នាចំពោះផែនការយុទ្ធសាស្ត្រក្រសួងផែនការដោយលៃយ៉ាងណាជួយកាត់បន្ថយបន្ទុកការងារផ្នែករដ្ឋបាលដល់ក្រសួងដើម្បីអោយបុគ្គលិករបស់ក្រសួងមានពេលវេលាគ្រប់គ្រាន់សំរាប់ការងារដូចជាការពិនិត្យឡើងវិញលើក្របខ័ណ្ឌពិនិត្យតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

### សូចនាករ ១.២: ច្របាច់បញ្ចូលគ្នានូវរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទាន

អង្គការមិនមែនរដ្ឋាភិបាលពុំពិនិត្យឃើញមានការវិវឌ្ឍន៍អ្វីទេចំពោះសូចនាការតាមដាននេះ ។

**iii) អនុសាសន៍**

- (១.១) អង្គការមិនមែនរដ្ឋាភិបាលសូមស្នើអោយក្រសួងចែករំលែកពត៌មានលំអិតជាងនេះស្តីពីផែនការយុទ្ធសាស្ត្រក្រសួងផែនការដោយមានបង្ហាញពីកាលបរិច្ឆេទនៃការអនុវត្តសកម្មភាពនានារបស់ផែនការនៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីផែនការនិងការកាត់បន្ថយភាពក្រីក្រ ។
- (១.១) ដោយហេតុថាផែនការយុទ្ធសាស្ត្រក្រសួងផែនការទើបតែបានអនុម័តកាលពីពាក់កណ្តាលឆ្នាំ ២០០៧ កន្លងទៅនេះ អង្គការមិនមែនរដ្ឋាភិបាលសូមស្នើអោយយកឆ្នាំ២០០៨ ជាឆ្នាំចាប់ផ្តើមសំរាប់អនុវត្តផែនការនេះ ។ នេះមានន័យថាម្ចាស់ជំនួយគួរមានការជួយគាំទ្រជាស្រេចសំរាប់ការអនុវត្តចាប់ពីឆ្នាំ ២០០៨ នេះទៅ ។
- (១.១) អង្គការមិនមែនរដ្ឋាភិបាលសូមស្នើឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ជួយគាំទ្រផែនការយុទ្ធសាស្ត្រក្រសួងផែនការរួមគ្នាជាជាងតាមរយៈគំរោងដាច់ដោយឡែកពីគ្នាដែលផ្តល់ផលប្រយោជន៍អោយតែក្រុមមនុស្សមួយចំនួនដែលបំរើការងារក្នុងគំរោងគាំទ្រដោយម្ចាស់ជំនួយប៉ុណ្ណោះ ។
- (១.១) អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍ចំពោះការលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រក្រសួងផែនការក្នុងការរៀបចំអោយមានអនុគណៈកម្មការនៅក្នុងក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រដើម្បីធ្វើការលើបញ្ហាជាក់លាក់ ។ ជាងនេះទៅទៀតក៏សូមស្នើអោយមានការពិភាក្សាពីការរៀបចំក្រុមការងារនេះដោយមានបញ្ចូលតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើការកែលំអប្រព័ន្ធពិនិត្យតាមដានផែនការយុទ្ធសាស្ត្រជាតិនៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រលើក្រោយនៅខែតុលាឆ្នាំ២០០៧ ។

# សុខាភិបាល

## i) សូចនាករតាមដានរួម

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវ |
|---|---|---|
| 4. បង្កើនចំនួននៃការសំរាលកូនដោយឆ្មបជំនាញ ក្នុងវិស័យសុខាភិបាលសាធារណៈ ឱ្យបាន៤៥% នៅខែធ្នូ ឆ្នាំ២០០៧ (៣៨% ក្នុងខែធ្នូ ឆ្នាំ២០០៦) | ១- ជ្រើសរើស និងបែងចែកឆ្មបយ៉ាងតិចចំនួន៦៨នាក់ឱ្យបាននៅចុងឆ្នាំ២០០៧ សម្រាប់មណ្ឌលសុខភាពចំនួន៦៨ ដែលបច្ចុប្បន្ននេះ មិនទាន់មានឆ្មប ។<br>២- ផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មប ។ ប្រាក់ឧបត្ថមត្រូវផ្តល់តាមចំនួននៃការសំរាលកូនដែលបានកំណត់ នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាលលេខ២៦៨ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧ ហើយកាំប្រៀវត្សរបស់ឆ្មប និងប្រាក់សងជំងឺចិត្តសម្រាប់គ្រោះថ្នាក់ ក្នុងវិជ្ជាជីវៈ ដែលទាក់ទងនឹងសុខភាព ដែលត្រូវបានស្នើឡើងដោយក្រសួងសុខាភិបាល នឹងត្រូវបានអនុម័តនៅក្នុងសម័យប្រជុំពេញអង្គរបស់ គណៈរដ្ឋមន្ត្រី ។ | ក្រសួងសុខាភិបាល |

## ii) វឌ្ឍនភាពដែលបានតាមដាន

ជាបឋមយើងសូមអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការរីកចំរើនជារួមនៃការបើកសាច់ប្រាក់ដល់ថ្នាក់ប្រតិបត្តិ។ ទោះបីជាមានការរីកចំរើនខ្លះៗយ៉ាងនេះក្តី ការបញ្ចេញសាច់ប្រាក់ជំពូកទី១៣ (ថវិកាកម្មវិធី — ពីមុនហៅថាថវិកាកម្មវិធីសកម្មភាពអទិភាព) នៅតែទាបដែលមិនអាចទទួលយកបាននៅឡើយនៅថ្នាក់ខេត្ត ជាពិសេសនៅក្នុងត្រីមាសទី១ និងត្រីមាសទី២នៃឆ្នាំ — ១.២២% និង៦.៨% ដោយឡែកៗពីគ្នា ។ ប្រការនេះនៅតែបន្តជះឥទ្ធិពលមិនល្អលើការផ្តល់សេវាសុខាភិបាលនៅតាមសហគមន៍។ សូចនាករនេះបច្ចុប្បន្នស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រុមការងារស្តីពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កិច្ចប្រជុំរវាងក្រសួងសុខា-ភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងដៃគូអភិវឌ្ឍន៍ ត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ទាក់ទងនឹងការបើកចំណាយសាច់ប្រាក់នេះ។ អង្គការមិនមែនរដ្ឋាភិបាលចង់អោយការពិភាក្សានេះបន្តមានរហូតដល់ការបញ្ចេញសាច់ប្រាក់ទៅថ្នាក់ប្រតិបត្តិត្រូវបានកែលំអជាពិសេសចំពោះវិស័យសង្គមទាំងពីរគឺវិស័យសុខាភិបាល និងអប់រំ។

### សូចនាករ ៤.១/២ បង្កើនអត្រានៃការសំរាលកូនដោយគ្រូពេទ្យជំនាញ

តាមពិតមានសូចនាករតែមួយប៉ុណ្ណោះនៅក្នុងសូចនការតាមដានរួមសំរាប់វិស័យសុខាភិបាល គឺការបង្កើនអត្រានៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលជំនាញ។ គេអាចដឹងពីភាពរីកចំរើននៃសូចនាករនេះបានតាមរយៈរបាយការណ៍របស់ប្រព័ន្ធពតិមានសុខាភិបាល ការអង្កេតប្រជាសាស្ត្រនិងសុខភាពរបស់ប្រទេសកម្ពុជា និងការពិនិត្យឡើងវិញលើផ្នែកឆ្មប ។ ការប្រមូល និងការវិភាគទិន្នន័យនៃការអង្កេតទាំងនេះ បច្ចុប្បន្ននេះកំពុងតែ

ដំណើរការ ។ ក៏ប៉ុន្តែ ការសម្រេចបាននូវសូចនាករដ៏សំខាន់នេះ (ក្នុងចំណោមសូចនាករលទ្ធផលផ្សេងជាច្រើនទៀតនៅក្នុងវិស័យសុខាភិបាល) ពឹងផ្អែកយ៉ាងខ្លាំងលើភាពរីកចំរើននៃការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង និងឱ្យក្លាយជាដៃគូអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។ ការរៀបចំគំរោងលើកទឹកចិត្តផ្អែកលើគុណសម្បត្តិកំពុងតែដំណើរការ និងពិភាក្សាដោយក្រសួងសុខាភិបាល ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងដៃគូអភិវឌ្ឍន៍ ហើយសកម្មភាពត្រៀមរៀបចំសេចក្តីព្រាងផែនការសកម្មភាពរួម រដ្ឋាភិបាល-ម្ចាស់ជំនួយសំរាប់ការអនុវត្តន៍ប្រាក់បៀវត្សរ៍បន្ថែមក៏កំពុងតែដំណើរការដែរ ។

**iii) អនុសាសន៍**

- (៤.២) អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពលើផ្នែកសុខាភិបាលកម្ពុជា សប្បាយចិត្តចំពោះកិច្ចប្រឹងប្រែងដ៏ខ្លាំងក្លា និងការរីកចំរើនដែលរាជរដ្ឋាភិបាលបានធ្វើកន្លងមក ។ ទោះជាយ៉ាងដូច្នេះក៏ដោយ យើងសូមឱ្យដៃគូទាំងអស់បន្តការងារលើការបញ្ចប់គំរោងលើកទឹកចិត្តផ្អែកលើគុណសម្បត្តិ និងធានាថាការផ្តល់បៀវត្សរ៍នឹងពិតជាផ្អែកលើគុណសម្បត្តិ និងបទពិសោធន៍ ។ ដោយហេតុថា គំរោងលើកទឹកចិត្តប្រាក់បៀវត្សរ៍ផ្អែកលើគុណសម្បត្តិ-ស្នាដៃ បច្ចុប្បន្នមានគោលបំណងផ្តោតលើក្រសួងនៅថ្នាក់កណ្តាលផងដែរនោះ អង្គការមិនមែនរដ្ឋាភិបាលក៏ជំរុញឱ្យដៃគូទាំងអស់ពង្រឹងការលើកទឹកចិត្ត និងការអនុវត្តន៍ការងារនៅថ្នាក់ផ្តល់សេវាផងដែរជាពិសេសនៅតាមតំបន់ជនបទ ។
- (៤.២) ដើម្បីបង្កើនអត្រានៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញប្រកបដោយប្រសិទ្ធភាព នោះទាមទារឱ្យមានការបែងចែកឆ្មបទៅតំបន់ជនបទដាច់ស្រយាល ។ អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍ដែលការពិនិត្យឡើងវិញលើផ្នែកឆ្មប នឹងក្លាយជាផ្នែកមួយនៃការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ដើម្បីឱ្យការលើកទឹកចិត្តចំពោះអ្នកប្រកបវិជ្ជាជីវៈផ្នែកសុខាភិបាល ជាពិសេសឆ្មបត្រូវបានដោះស្រាយ និងបោះជំហានទៅមុខបានឆាប់រហ័ស ។

# វិស័យកសិកម្ម និងទឹក

### i) សូចនាករតាមដានរួម

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរដ្ឋាភិបាល ដែលទទួលខុសត្រូវ |
|---|---|---|
| ៧. អនុវត្ត និងត្រួតពិនិត្យភាព ជាដៃគូ ក្នុងការអនុវត្តនីបណ្ដា អាទិភាពនៃវិស័យកសិកម្ម និងទឹក | ១- អនុវត្តជំហាន១ នូវយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ស្របតាម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ :<br>ក- សម្រេចកិច្ចព្រមព្រៀងស្ដីពីគោលការណ៍ សម្រាប់ណែនាំ ដៃគូអភិវឌ្ឍន៍ និងក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលបំពេញ ការងារក្នុងវិស័យកសិកម្ម និងទឹក នាចុងខែមិថុនា ឆ្នាំ២០០៧<br>ខ- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងដៃគូអភិវឌ្ឍន៍ អនុម័តល័ក្ខខ័ណ្ឌយោងសម្រាប់ រៀបចំកម្មវិធីទាំង៥ នៃយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក នាខែកក្កដា ឆ្នាំ២០០៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងធនធានទឹក និង ឧតុនិយម |
| | គ- រៀបចំបញ្ចប់កម្មវិធីជាតិចំនួន២ នាចុងខែធ្នូ ឆ្នាំ២០០៧ និង | |
| | ឃ- រៀបចំបញ្ចប់កម្មវិធីជាតិចំនួន៥ នាចុងខែមិថុនា ឆ្នាំ២០០៨ | |
| | ២- កែលំអការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដោយ:<br>ក- ភាគីពាក់ព័ន្ធទទួលបានព័ត៌មានស្ដីពីសកម្មភាពទាំងអស់ តាមរយៈការធ្វើ បច្ចុប្បន្នភាពព័ត៌មាន២ដងក្នុងមួយឆ្នាំ (ចុងខែមិថុនា និងចុងខែធ្នូ) នៅលើ គេហទំព័ររបស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យ កសិកម្ម និងទឹក។ | |

### ii) វឌ្ឍនភាពដែលបានតាមដាន

**សូចនាករ ៧.១ក/ខ/គ/ឃ: ការអនុវត្តយុទ្ធសាស្ត្រសំរាប់វិស័យកសិកម្មនិងធនធានទឹក**

៧.១ក/ខ/គ/ឃ: យោងតាមការប្រជុំជាមួយមន្ត្រីនៅលេខាធិការដ្ឋានក្រុមការងារ បច្ចេកទេសស្ដីពី កសិកម្ម និងទឹក នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំណុចទាំងបួននេះមិនទាន់បានអនុវត្តនៅឡើយទេ ហើយសកម្មភាពទាំងនេះនឹងយកមកពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្ដីពីកសិកម្មនិងទឹកនៅចុង ខែកញ្ញាឆ្នាំ២០០៧។

៧.២ក: ចាប់តាំងពីចុងខែមិថុនា ឆ្នាំ២០០៧ ពត៌មានដែលទាក់ទងនឹងសកម្មភាពមូលដ្ឋាន ទិន្នន័យគំរោង ស្ដីពីបញ្ជីសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាលនៅក្នុងវិស័យកសិកម្ម និងទឹក មិនទាន់បានធ្វើបច្ចុប្បន្នភាព

នៅលើវិបសាយ (http://www.twgaw.org/index.php) ដែលបានរៀបចំដោយ TWG-AW កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧។

**iii) អនុសាសន៍**

- អង្គការមិនមែនរដ្ឋាភិបាលបំរើការលើវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទសូមស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភាគីពាក់ព័ន្ធទាំងអស់ពិចារណានិងបន្តធ្វើការលើសកម្មភាពទាំងនេះ។
- អង្គការមិនមែនរដ្ឋាភិបាលក៏ផ្តល់អនុសាសន៍ផងដែរថាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម គួរធ្វើបច្ចុប្បន្នភាពរាល់ពតិមានទាំងអស់ដែលទាក់ទងនឹងសកម្មភាពមូលដ្ឋានទិន្នន័យគំរោងរបស់ដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលនៅក្នុងវិស័យកសិកម្ម និងទឹកនៅលើគេហ-ទំព័ររបស់ខ្លួនឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

# កំណែទម្រង់ដីធ្លី

## i) សូចនាករតាមដានរួម

| គោលដៅ | សកម្មភាព | ស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវ |
|---|---|---|
| ៨. អនុវត្តបទដ្ឋានគតិយុត្តិទាំងឡាយនៃច្បាប់ភូមិបាល | ១. អនុមតិគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការចុះបញ្ជី និង សិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និងចាត់វិធានការការពារបឋម ( អត្តសញ្ញាណដី ការធ្វើផែនទីដីធ្លី រៀបចំចំណាត់ថ្នាក់ដី និងការអនុញ្ញាតបណ្តោះអាសន្នលើដីដែលជនជាតិដើមភាគតិចបានទាមទារតាមច្បាប់) ដើម្បីការពារដីរបស់សហគមន៍ជនជាតិដើមភាគតិចទាំងនេះ នៅខេត្តចំនួន ២ ក្នុងក្របខ័ណ្ឌរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងក្រុមការងារស្រុក ដូចមាន ចែងក្នុង អនុក្រិត្យលេខ ១១៨។<br><br>២. លើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជនក្រីក្រតាមជនបទ ពោលគឺ ប្រជាជនចំនួន ៥០០ គ្រួសារអាចតាំងទីលំនៅលើដីសម្បទាន សង្គមកិច្ច ដោយមានការគាំទ្រខាងជីវភាពរស់នៅ និង យ៉ាងតិច មានដី ចំនួន ១០.០០០ ហ.ត ទៀត ត្រូវបានរក្សាសម្រាប់សម្បទាន សង្គមកិច្ច។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់<br><br>ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារដីធ្លី |

## ii) វឌ្ឍនភាពដែលបានតាមដាន

### សូចនាករ ៨.១: សិទ្ធិប្រើប្រាស់ដីរបស់ជនជាតិដើមភាគតិច

ទោះបីអង្គការមិនមែនរដ្ឋាភិបាលស្វាគមន៍ការផ្តល់អាទិភាពជាបន្តលើសន្តិសុខកាន់កាប់ដីធ្លីសម្រាប់ជនជាតិដើមភាគតិចតាមរយៈការជ្រើសរើសចំណុចនេះជាសូចនាករតាមដានរួមមួយនៃសូចនាករតាមដានរួមផ្នែកកំណែទម្រង់ដីធ្លីតែពីរប៉ុណ្ណោះក្នុងឆ្នាំ២០០៧ក្តី ក៏គេឃើញមានការបារម្ភច្រើនអំពីការងាកចេញពីគោលដៅនៃ "ការចុះបញ្ជីសិទ្ធិប្រើប្រាស់ដីធ្លីរបស់ជនជាតិដើមភាគតិច" ដូចដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ទៅកាន់ការអនុមតិគោលនយោបាយមួយស្តីពី "ការចុះបញ្ជី និង សិទ្ធិប្រើប្រាស់" និង ការសាកល្បង "វិធានការការពារបឋម" នៅក្នុងខេត្តចំនួនពីរតែប៉ុណ្ណោះ។ អង្គការមិនមែនរដ្ឋាភិបាល និង ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់សង្ឃឹមថា តាមរយៈការបោះឆ្នោតគាំទ្រសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច រាជរដ្ឋាភិបាលកម្ពុជាកំពុងបង្ហាញនូវការវិលត្រឡប់ទៅកាន់ការអនុមតិគាំទ្រសិទ្ធិរបស់ជនជាតិដើមភាគតិចកម្ពុជាចំពោះកម្មសិទ្ធិដីរួម ដោយអនុលោមតាម "ការការពារពិសេស" ដែលមានចែងនៅក្នុងមាត្រា ២៤ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

អង្គការមិនមែនរដ្ឋាភិបាលបន្តមានការបារម្ភអំពីខ្លឹមសារនៃ "គោលនយោបាយស្តីពីការចុះបញ្ជីនិងសិទ្ធិប្រើប្រាស់ដីសហគមន៍របស់ជនជាតិដើមភាគតិច" និង ដំណើរការដែលតាមរយៈនោះគោលនយោបាយនេះត្រូវបានតាក់តែង។ សេចក្តីព្រាងគោលនយោបាយបច្ចុប្បន្ន ធ្វើឱ្យខូចខាតដល់បញ្ញត្តិមួយចំនួននៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ ដូចជា:

- ជម្រុញប្រពលវប្បកម្មកសិកម្ម និង បញ្ឈប់ការធ្វើកសិកម្មផ្លាស់ទីកន្លែង (ច្បាប់ភូមិបាលគោរពយ៉ាងច្បាស់លាស់នូវទំនៀមទម្លាប់គ្រប់គ្រងដីធ្លី)
- ដាក់កំហិតលើទំហំនៃនៃព្រៃឈើជំនឿនិងព្រៃឈើកប់សព (ច្បាប់ភូមិបាលចែងថាដីនេះត្រូវចុះបញ្ជីផ្អែកលើស្ថានភាពជាក់ស្តែង តាមការអះអាងដោយសហគមន៍និងអ្នកជិតខាង)។

ចំពោះដំណើរការ គេពុំឃើញមានការផ្តល់ឱកាសសម្រាប់ការពិគ្រោះយោបល់អំពីសេចក្តីព្រាងថ្មីទាំងនេះជូនដល់អ្នកដែលរងផលប៉ះពាល់ ឬក្រុមសង្គមស៊ីវិលដែលធ្វើការងារលើបញ្ហាទាំងនេះឡើយ។ ប្រការនេះមានលក្ខណៈគួរឱ្យបារម្ភជាពិសេស ដោយសារសេចក្តីព្រាងមុនត្រូវបានបដិសេធដោយជនជាតិដើមភាគតិចខ្លួនឯងនៅក្នុងពេលពិគ្រោះយោបល់ជាមួយតំណាងរាជរដ្ឋាភិបាល កាលពីខែ មករា និង កុម្ភៈ ឆ្នាំ ២០០៧។

ទោះបីរបាយការណ៍វឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសស្តីពីដីធ្លីលើកឡើងថា ផែនការសកម្មភាពដំបូងសម្រាប់ការអនុវត្តន៏វិធានការការពារបឋម ដើម្បីការពារដីរបស់សហគមន៍ជនជាតិដើមភាគតិចកំពុងត្រូវបានតាក់តែងក្តី ក៏អង្គការមិនមែនរដ្ឋាភិបាលសូមជំរុញយ៉ាងខ្លាំងក្លាសូមឱ្យរាជរដ្ឋាភិបាលចាត់វិធានការជាក់ស្តែងដើម្បីធានាឱ្យបានថាវិធានការការពារបឋមត្រូវបានអនុវត្តជាបន្ទាន់ ដើម្បីទប់ស្កាត់ការចាប់ យកដីរបស់ជនជាតិដើមភាគតិចរៀងរាល់ថ្ងៃដែលកើតឡើងនៅក្នុងខេត្តគោលដៅទាំងពីរ។ លើសពីនេះទៀត គេឃើញមានការបារម្ភដែលថារបាយការណ៍ក្រុមការងារបច្ចេកទេសដីធ្លីនេះបកស្រាយសូចនាករនេះក្នុងន័យយ៉ាងតូចចង្អៀតដោយសំដៅតែទៅលើវិធានការការពារបឋមប៉ុណ្ណោះនៅក្នុងសហគមន៍ជនជាតិដើមភាគតិចសាកល្បងទាំងបី ដែលត្រូវបានទទួលស្គាល់ជានីតិបុគ្គល ជាជាងពង្រីកទៅដល់សហគមន៍ជនជាតិដើមភាគតិចផ្សេងទៀតនៅក្នុងខេត្តទាំងពីរនេះដូចមានចែងនៅក្នុងសូកម្មភាពរបស់សូចនាករតាមដានរួម។

**សូចនាករ ៨.២: ដីសម្បទានសង្គមកិច្ច**

សូចនាករនេះត្រូវបានរំកិលពីសូចនាករឆ្នាំ២០០៦។ អង្គការមិនមែនរដ្ឋាភិបាលមានការច្របូកច្របល់អំពីតួលេខខុសៗគ្នាដែលផ្តល់សម្រាប់ដីដែលបានចុះបញ្ជីជាដីឯកជនរដ្ឋ ជាជំហានទីមួយនៅក្នុងដំណើរការបែងចែកដីនៅទីតាំង សាកល្បងនៃគម្រោង LASED នៅខេត្តក្រចេះ:

- អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅខេត្តក្រចេះរាយការណ៍ថាដីប្រហែល ៧.០០០ ហ.ត ត្រូវបានចុះបញ្ជីរួច។

- របាយការណ៍វឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារដីធ្លី របាយការណ៍ថាដី ៣.៩០៣,៩៧ ហ.ត ត្រូវបានចុះបញ្ជីរួច ក្នុងនោះដី ៣.២៩៤,៣៦ ហ.ត នៅឃុំសម្បុក និង ដី ៦១២,២១ ហ.ត នៅឃុំចងក្រង ស្រុកក្រចេះ។
- របាយការណ៍ "អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា" ស្តីពីវឌ្ឍនភាពដែលសម្រេចបាន ប្រៀបធៀបនឹង JMIs នៅក្នុងឆ្នាំ ២០០៦ បានលើកឡើងថាមកដល់ខែ ឧសភា ឆ្នាំ ២០០៧ ដី ៤.៤០០ ហ.ត ត្រូវបានចុះបញ្ជីរួចហើយជាដីឯកជនរដ្ឋ នៅក្នុងឃុំសម្បុក និង ឃុំចងក្រង[១]។

អង្គការមិនមែនរដ្ឋាភិបាលក៏កត់សម្គាល់ផងដែរថា ទោះបីជា JMI នេះត្រូវបានរំកិលពីឆ្នាំ ២០០៦ ក្តី ក៏ដីមិនបានពាក់កណ្តាលនៃគោលដៅ១០.០០០ ហ.ត ទេដែលត្រូវបានកំណត់ឬចុះបញ្ជីមកដល់ពេលនេះ ជាការរៀបចំសម្រាប់បែងចែកជាដីសម្បទានសង្គមកិច្ច។

មានតែអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចប៉ុណ្ណោះដែលធ្វើការនៅក្នុងខេត្តក្រចេះដែលបានរាយ-ការណ៍អំពីការទទួលបានពត៌មានទាក់ទិននឹងគម្រោង LASED ហើយអង្គការមិនមែនរដ្ឋាភិបាលភាគច្រើនបានលើកឡើងអំពីការលំបាកខ្លាំងក្នុងការចូលរួមក្នុងគម្រោងនេះ ដោយសារការសម្របសម្រួលមិនបានល្អ និង ការផ្តល់ដំណឹងជាមុនមិនបានទាន់ពេលមុនពេលមានកិច្ចប្រជុំ។

ទោះបីជាមានការរាយការណ៍ជូនដល់កិច្ចប្រជុំចុងក្រោយរបស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារដីធ្លី ថាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅខេត្តក្រចេះបានផ្តល់ជំនួយនៅក្នុងរយៈពេលជ្រើសរើសអ្នកទទួលដីក្តី ក៏អង្គការមិនមែនរដ្ឋាភិបាលខ្លួនឯងបានរាយការណ៍ថា ដំណើរការនេះមានលក្ខណៈស្មុគស្មាញជ្រុលពេក និង មានលក្ខណៈយឺតពេក។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនមានការបារម្ភថាគ្រួសារទាំងឡាយអាចជួបការលំបាកក្នុងការស្ថិតនៅលើទីតាំងដីសម្បទានសង្គមកិច្ចដែលបានបែងចែកឱ្យពួកគេ ដោយសារហេដ្ឋារចនាសម្ព័ន្ធមិនល្អ និង ជម្រើសជីវភាពដ៏មានកម្រិត។

**iii) អនុសាសន៍**

## សូចនាករ ៨.១: សិទ្ធិប្រើប្រាស់ដីរបស់ជនជាតិដើមភាគតិច

- ធ្វើការពិគ្រោះយោបល់បន្ថែមទៀតជាមួយសហគមន៍ជនជាតិដើមភាគតិច និង ក្រុមសង្គមស៊ីវិលដែលកំពុងជួយទ្រទ្រង់ជនជាតិដើមភាគតិច ក្នុងការពិនិត្យមើលឡើងវិញនូវសេចក្តីព្រាងគោលនយោបាយស្តីពីការចុះបញ្ជីនិងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និង ធានាឱ្យបានថាបញ្ញត្តិនៃ

[១] រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០៧ "ការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា: របាយការណ៍ស្តីពីវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅនៃសូចនាករតាមដានរួមដែលបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ដែលប្រព្រឹត្តទៅក្នុង ខែ មីនា ឆ្នាំ ២០០៦" ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, បានធ្វើបច្ចុប្បន្នភាពនៅ ខែ ឧសភា ឆ្នាំ ២០០៧។

គោលនយោបាយនេះបំពេញបន្ថែម និង ស្របតាមស្មារតីនៃច្បាប់ភូមិបាលឆ្នាំ ២០០១ រដ្ឋធម្មនុញ្ញកម្ពុជា និង បទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងទៀត។

- គេត្រូវតែអនុមតិយកការបកស្រាយ JMI ៨.១ កាន់តែទូលាយ ដែលចាត់វិធានការនានាដើម្បីអនុវត្ត វិធានការការពារបឋមដើម្បីការពារដីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងទូទាំងខេត្តទាំងពីរ ជាជាង ត្រឹមតែភូមិសាកល្បងទាំងបី ហើយដោយហេតុដូចនេះត្រូវផ្តោតលើសហគមន៍ជនជាតិដើមភាគតិចទាំងអស់ រួមទាំងសហគមន៍ជនជាតិដើមភាគតិចទាំងឡាយដែលមិនទាន់បានចុះបញ្ជីជានីតិបុគ្គលស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១។
- បញ្ចប់ផែនការសកម្មភាពដំបូងឱ្យបានលឿន ដោយពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃក្រុមការងារបច្ចេកទេសការងារដីធ្លី និងចាប់ផ្តើមអនុវត្តជាបន្ទាន់នូវវិធានការការពារទាំងឡាយ ដូចមានអធិប្បាយនៅក្នុងសកម្មភាព JMI ៨.១ ពោលគឺ "អត្តសញ្ញាណដី ការធ្វើផែនទីដីធ្លី ការរៀបចំចំណាត់ថ្នាក់ដី និង ការអនុញ្ញាតបណ្តោះអាសន្នលើដីដែលជនជាតិដើមភាគតិចបានទាមទារតាមច្បាប់"។
- ក្របខ័ណ្ឌពេលវេលាច្បាស់លាស់សម្រាប់ការអនុវត្តន៍សកម្មភាពនានាដែលមានកំណត់នៅក្នុង JMI ៨.១ ត្រូវតែត្រូវបានរៀបចំ និង ផ្សព្វផ្សាយ ដើម្បីឃ្លាំមើលវឌ្ឍនភាពមុនការិយបរិច្ឆេទនៃកិច្ចប្រជុំ CDCF ខាងមុខនៅក្នុងខែ ធ្នូ ឆ្នាំ ២០០៨។

**សូចនាករ JMI ៨.២: ដីសម្បទានសង្គមកិច្ច**

- បង្កើនល្បឿនលើដំណើរការជ្រើសរើសអ្នកទទួលដីនៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចសាកល្បងនៅខេត្តក្រចេះ និង បំភ្លឺចំនួនដីដែលបានចុះបញ្ជីហើយជាដីឯកជនរដ្ឋ។
- បង្កើនល្បឿនលើដំណើរការនៃការកំណត់ផែនទីដីរដ្ឋ ជាយន្តការមួយសម្រាប់កំណត់ទីតាំងដីសម្បទានសង្គមកិច្ចដែលអាចមាននៅតាមតំបន់គោលដៅផ្សេងទៀត រួមទាំងទីតាំងនៅទីក្រុង និង កែលម្អសុខុដុមនីយកម្មនៃដំណើរការបែងចែកដី ជាមួយនឹងគម្រោងទ្រទ្រង់កិច្ចអភិវឌ្ឍន៍ និង គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធ។
- បង្កើតឱ្យទៅជាផ្លូវការនូវដំណើរការដែលអង្គការមិនមែនរដ្ឋាភិបាលចូលរួមនៅក្នុងដំណើរការនៃដីសម្បទានសង្គមកិច្ច ជាពិសេសជាអ្នកឃ្លាំមើលឯករាជ្យលើការជ្រើសរើសអ្នកទទួលដី។
- ក្របខ័ណ្ឌពេលវេលាច្បាស់លាស់សម្រាប់ការអនុវត្តន៍សកម្មភាពនានាដែលមានកំណត់នៅក្នុង JMI ៨.២ ត្រូវតែរៀបចំ និង ផ្សព្វផ្សាយ ដើម្បីឃ្លាំមើលវឌ្ឍនភាពមុនការិយបរិច្ឆេទនៃកិច្ចប្រជុំ CDCF ខាងមុខនៅក្នុងខែ ធ្នូ ឆ្នាំ២០០៨។

# កំណែទម្រង់ព្រៃឈើ

## i) សូចនាករតាមដានរួម

| គោលដៅ | សកម្មភាព | ស្ថាប័នរដ្ឋាភិបាល ដែលទទួលខុសត្រូវ |
|---|---|---|
| ៩. ក្នុងគោលបំណងបញ្ឈប់ការបាត់បង់ធនធានព្រៃឈើនៅកម្ពុជា ត្រូវអនុវត្តឱ្យបានពេញលេញ នៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាលនូវក្របខ័ណ្ឌគតិយុត្តិទាំងឡាយស្របតាមច្បាប់ស្តីពីការគ្រប់គ្រងព្រៃឈើ ពិសេស ការអនុវត្តន៏អនុក្រិត្យស្តីពីដីសម្បទានសេដ្ឋកិច្ច | ១. អនុវត្តអនុក្រិត្យស្តីពីដីសម្បទានសេដ្ឋកិច្ចនិងរៀបចំសៀវភៅកត់ត្រាអំពីដីសម្បទានសេដ្ឋកិច្ចសម្រាប់ផ្សព្វផ្សាយជាសាធារណៈ រួមទាំងការសម្រេចរបស់ខេត្តក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច ពិនិត្យឡើងវិញការផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលមានទំហំធំ ជាង ១០.០០០ ហ.ត ចំនួនយ៉ាងតិច ៥ កន្លែង ចាត់វិធានការសមស្រប ដោយអនុលោមតាមជំពូកទី ៦ នៃអនុក្រិត្យស្តីពីដីសម្បទានសេដ្ឋកិច្ច។<br><br>២. អនុវត្តឱ្យបានឆាប់ និងទូលំទូលាយទូទាំងប្រទេសនូវការកំណត់ព្រំដែនដីព្រៃឈើ ស្របតាមអនុក្រិត្យលេខ ៥៣ ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ២០០៥។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br><br>ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារព្រៃឈើនិងបរិស្ថាន<br><br>ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារដីធ្លី |

## ii) វឌ្ឍនភាពដែលបានតាមដាន

### សូចនាករ ៩.១: ដីសម្បទានសេដ្ឋកិច្ច

អង្គការមិនមែនរដ្ឋាភិបាលពេញចិត្តនឹងការលុបចោលជាបន្តបន្ទាប់នូវដីសម្បទានសេដ្ឋកិច្ច ដោយសារការមិនបានគោរពទៅតាមក្របខ័ណ្ឌច្បាប់ដូចជាដីសម្បទានចំនួន ៧ ដែលត្រូវបានលុបចោលនៅខេត្តកំពង់ស្ពឺ កំពង់ធំ ក្រចេះ និង មណ្ឌលគិរី ដែលមានផ្ទៃដីសរុប ៦៦.៩៦០ ហ.ត។ ប៉ុន្តែ យើងកត់សម្គាល់ឃើញថា ពុំមានការរាយការណ៍អំពីវឌ្ឍនភាពពាក់ព័ន្ធនឹងការកាត់បន្ថយដីសម្បទានសេដ្ឋកិច្ចចំនួន ១១ ដែលបច្ចុប្បន្នកំពុង ដំណើរការលើសពីការកំណត់ទំហំស្របច្បាប់ ១០.០០០ ហ.ត ដូចដែលបានរាយការណ៍ដោយអង្គការមិនមែន រដ្ឋាភិបាលដែលធ្វើការងារនៅថ្នាក់ខេត្ត ឬ នៅក្នុងរបាយការណ៍វឌ្ឍនភាពដែលដាក់ជូនដោយក្រុមការងារបច្ចេក ទេសការងារព្រៃឈើ និងបរិស្ថាន (TWG-F&E) ដែលលើកឡើងថា "ក្រុមហ៊ុនចំនួន ៥ នៅក្នុងចំណោមក្រុមហ៊ុនចំនួន ៨ ដែលមានដីសម្បទានសេដ្ឋកិច្ចធំជាង ១០.០០០ ហ.ត កំពុងត្រូវបានពិគ្រោះយោបល់ដើម្បីកាត់បន្ថយ ឱ្យនៅត្រឹម ១០.០០០ ហ.ត"[២]។

[២] គេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទបង្ហាញថាមានសម្បទានសរុបចំនួន ៥១ ដែលកំពុងដំណើរការបច្ចុប្បន្ន ដែលនៅក្នុង នោះ សម្បទានចំនួន ៨ មានទំហំធំជាង ១០.០០០ ហ.ត។ ប៉ុន្តែ ទិន្នន័យដែលរៀបចំឡើងដោយក្រុមសង្គមស៊ីវិលបង្ហាញថាមមានសម្បទាន សរុបចំនួន ៦១ ដែលនៅក្នុងនោះ សម្បទានចំនួន ១១ កំពុងដំណើរការលើសការកំណត់ទំហំស្របច្បាប់។

យើងក៏សូមស្វាគមន៍ផងដែរនូវការដាក់បញ្ចូលដីសម្បទានសេដ្ឋកិច្ចដែលបានសម្រេចនៅថ្នាក់ខេត្តនៅក្នុងក្របខ័ណ្ឌនៃ JMI ថ្មីនេះ។ ហេតុនេះ យើងខ្ញុំសូមអំពាវនាវដល់សមាជិកទាំងឡាយក្រុមការងារបច្ចេកទេសដ្ឋីពីព្រៃឈើនិងបរិស្ថានសូមឱ្យខិតខំគោរពតាមការិយបរិច្ឆេទខែធ្នូ ឆ្នាំ២០០៧ សម្រាប់បញ្ចេញពត៌មានអំពី សម្បទានដែលបានសម្រេចនៅថ្នាក់ខេត្តទាំងនេះ ទោះបីជាមានការលំបាកក្នុងការទទួលបានពត៌មានដូចដែលបានលើកឡើងថាជាឧបសគ្គមួយនៅក្នុងរបាយការណ៍វឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថានក្តី។ យើងខ្ញុំក៏មានការបារម្ភផងដែរអំពីរបាយការណ៍បច្ចុប្បន្ន (ប៉ុន្តែនៅមិនទាន់បានផ្ទៀងផ្ទាត់នៅឡើយ) ពីអង្គការមិនមែនរដ្ឋាភិបាលដែលថាសម្បទានដែលមានទំហំធំជាងការកំណត់អតិបរមា ១.000 ហ.ត កំពុងត្រូវបានអនុមតិដោយអាជ្ញាធរខេត្តផងដែរ។

### សូចនាករ ៩.២: ការកំណត់ព្រំដែនព្រៃឈើ

អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍ចំពោះការអនុមតិគោលការណ៍ណែនាំស្តីពីឧបករណ៍កំណត់ព្រំដែនសំរាប់កំណត់ព្រំដែនមណ្ឌលព្រៃឈើអចិន្ត្រៃដោយរដ្ឋបាលព្រៃឈើ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ឆ្នាំ២០០៧) និងមានសេចក្តីរីករាយដែលគោលការណ៍ណែនាំនេះត្រូវបាន ផ្សព្វផ្សាយជូនដល់ការិយាល័យរដ្ឋបាលព្រៃឈើ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលធ្វើប្រតិបត្តិការនៅក្នុងវិស័យព្រៃឈើ។ ប៉ុន្តែ មានការកត់សម្គាល់ឃើញថាអង្គការមិនមែនរដ្ឋាភិបាលភាគច្រើនដែលធ្វើការងារនៅក្នុងវិស័យនេះ ឬ សហគមន៍ដែលរងផលប៉ះពាល់មិនទាន់បានទទួលនៅឡើយនូវឯកសារផ្សេងទៀត ដូចជារបាយការណ៍ស្ថិតិ ព្រៃឈើកម្ពុជាឆ្នាំ ២០០៦ អំពីការធ្វើចំណាត់ថ្នាក់ព្រៃឈើរដ្ឋ ការកំណត់ព្រំដែននិងការកំណត់ផែនទីដែលបានចេញ ផ្សាយនៅក្នុងខែ ឧសភា ឆ្នាំ២០០៧។

ក្រៅពីនេះអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅថ្នាក់ខេត្ត បានកត់សម្គាល់ឃើញថាមានវឌ្ឍនភាពតិចតួច ហើយគេពុំអាចធ្វើការផ្ទៀងផ្ទាត់ឯករាជ្យបានទេលើរបាយការណ៍វឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថានដែលថាព្រំដែនព្រៃឈើ ១៧០ គម ត្រូវបានកំណត់រួចហើយ។

## iii) អនុសាសន៍

### សូចនាករ ៩.១: ដីសម្បទានសេដ្ឋកិច្ច

- បង្កើនល្បឿនលើការពិនិត្យឡើងវិញនូវដីសម្បទានសេដ្ឋកិច្ចបច្ចុប្បន្នដែលទំហំលើសពីការកំណត់ស្របច្បាប់ ១០.000 ហ.ត ស្របតាមបទប្បញ្ញត្តិនៃអនុក្រិត្យស្តីពីដីសម្បទានសេដ្ឋកិច្ច។ ចំណុចនេះត្រូវតែធានាឱ្យបានថាសម្បទានត្រូវបានហាមឃាត់នៅលើដីឯកជន និង ដីដែលអាចមានកម្មសិទ្ធិសហគមន៍ដោយជនជាតិដើមភាគតិច ស្របតាមស្មារតីនៃរបាយការណ៍ខែមិថុនា ឆ្នាំ២០០៧ ស្តីពី "ការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា" ដែលលើកឡើងថា "ដីសម្បទានសេដ្ឋកិច្ច បច្ចុប្បន្ននិងអនាគតត្រូវបានផ្តល់តែនៅលើដីរិចរិលដែលគ្មានលទ្ធភាពសម្រាប់ការដាំដើមឈើ ឬ អភិវឌ្ឍន៍ព្រៃឈើ

តែប៉ុណ្ណោះ។ ដីឯកជន និង ដីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានហាម ឃាត់យ៉ាងតឹងរ៉ឹង ចំពោះការធ្វើដីសម្បទានសេដ្ឋកិច្ច។[៣]"

- សមាជិកនៃក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថានត្រូវតែខិតខំដើម្បីធានា ឱ្យបានថាបុគ្គលិកក្រសួងពាក់ព័ន្ធដែលបំពេញការងារនៅថ្នាក់ខេត្តបញ្ចេញពត៌មានទាំងអស់ដែល ទាក់ទិននឹងដីសម្បទានសេដ្ឋកិច្ចដែលបានសម្រេចនៅថ្នាក់ខេត្ត កែលម្អតម្លាភាពនិងគណនេយ្យភាព ប្រតិបត្តិការរបស់ខ្លួន និងតាមដានការសម្រេចនានាដើម្បីធានាឱ្យបានថាការសម្រេចទាំងនេះគោរព តាមការកំណត់ទំហំ ១.០០០ ហ.ត។
- ពត៌មានថ្មីដែលបានបញ្ចេញនៅក្នុងក្រុមងារបច្ចេកទេសការងារដីធ្លី បង្ហាញថាតំបន់ដីសម្បទានសេដ្ឋកិច្ចដែលបានលុបចោលនឹងត្រូវបានពិចារណាសម្រាប់បែងចែកឡើងវិញជាទីតាំង ដីសម្បទានសង្គមកិច្ចសាកល្បងទីបី ជាពិសេសដីសម្បទានសេដ្ឋកិច្ចទាំង ៤ នៅខេត្តកំពង់ស្ពឺ និង ដីសម្បទានសេដ្ឋកិច្ច ១ នៅខេត្តកំពង់ធំដែលទើបបានលុបចោលនៅពេលថ្មីៗនេះ។ ប៉ុន្តែសូមផ្តល់ជា អនុសាសន៍សូមឱ្យធ្វើការវិភាគឱ្យបានសមស្របជាមុន (រួមទាំងការពិគ្រោះយោបល់សាធារណៈផង) អំពីស្ថានភាពនៃតំបន់ទាំងនេះរួមទាំងគម្របដី ការកាន់កាប់និងការប្រើប្រាស់ដីបច្ចុប្បន្នដោយ សហគមន៍មូលដ្ឋាន។
- ក្របខ័ណ្ឌពេលវេលាច្បាស់លាស់សម្រាប់ការអនុវត្តន៏សកម្មភាពនានាដែលមានកំណត់នៅក្នុង JMI ៩.១ ត្រូវតែរៀបចំ និង ផ្សព្វផ្សាយ ដើម្បីឃ្លាំមើលវឌ្ឍនភាពមុនការិយបរិច្ឆេទនៃកិច្ចប្រជុំ CDCF ខាងមុខនៅក្នុងខែធ្នូ ឆ្នាំ២០០៨។

**សូចនាករ ៩.២: ការកំណត់ព្រំដែនព្រៃឈើ**

- អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវដល់សមាជិកនៃក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថានសូមឱ្យបង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីផ្សព្វផ្សាយពត៌មាននិងរបាយការណ៍វឌ្ឍនភាពនានាជូនដល់អង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើការងារនៅក្នុងវិស័យព្រៃឈើ ហើយលើសពីនេះទៀតសូមបង្កើតយន្តការនានាដើម្បីផ្សារភ្ជាប់ក្រុមសង្គមស៊ីវិលឱ្យបានកាន់តែខ្លាំងថែមទៀតនៅក្នុងការងារកំណត់ព្រំដែនព្រៃឈើ។
- ក្របខ័ណ្ឌពេលវេលាច្បាស់លាស់សម្រាប់ការអនុវត្តន៏សកម្មភាពនានាដែលមានកំណត់នៅក្នុង JMI ៩.២ ត្រូវតែរៀបចំ និង ផ្សព្វផ្សាយ ដើម្បីឃ្លាំមើលវឌ្ឍនភាពមុនការិយបរិច្ឆេទនៃកិច្ចប្រជុំ CDCF ខាងមុខនៅក្នុងខែធ្នូ ឆ្នាំ ២០០៨។

---

[៣] រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ ២០០៧) "ការអនុវត្តន៏គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាៈ របាយការណ៍ស្តីពីវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅទាំងឡាយនៃសូចនាករតាមដានរួមដែលត្រូវបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់នៅក្នុងខែ មីនា ឆ្នាំ ២០០៦" ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៏កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា , ធ្វើបច្ចុប្បន្នភាពនៅក្នុងខែ ឧសភា ឆ្នាំ ២០០៧។

# វិស័យជលផល

## i) សូចនាករតាមដានរួម

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវ |
|---|---|---|
| ១០. ចាត់វិធានការសមស្រប ដើម្បីឆ្លុះបញ្ចាំងពីអាទិភាពនៃវិស័យជលផលសម្រាប់លើក កំរិតជីវភាពរស់នៅរបស់ សហគមន៍ជនបទទៅក្នុង ផែនការអភិវឌ្ឍន៍ឃុំ ស្រុក និង ខេត្ត ដោយបញ្ជាក់អំពីកំរិត នៃការផ្តល់ហិរញ្ញប្បទាន របស់ដៃគូអភិវឌ្ឍន៍ | ១. ពង្រាងបញ្ចប់នូវក្រមប្រតិបត្តិសម្រាប់ការងារជលផល នាចុងឆ្នាំ ២០០៧ ។<br>២. ពិភាក្សាជាមួយ និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឱ្យរដ្ឋបាលជលផលមាន ហិរញ្ញប្បទានគ្រប់គ្រាន់ (គិតទាំងចំណូលដែលបាន មកពីវិស័យនេះ) សម្រាប់អនុវត្តកាតព្វកិច្ចរបស់ខ្លួន ស្របតាមមាត្រាទី ១៤ នៃច្បាប់ជលផល ។<br>៣. ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធផែនការ គណនេយ្យ និង ត្រួតពិនិត្យរបស់រដ្ឋបាលជលផល ស្របតាមក្របខ័ណ្ឌ ចំណាយរយៈពេលមធ្យម និងប្រព័ន្ធ ប្រាក់បៀវត្សស្របតាមប្រសិទ្ធភាពការងារ នាចុងឆ្នាំ២០០៧។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |

## ii) វឌ្ឍនភាពដែលបានតាមដាន

### សូចនាករ ១០.១: ពង្រាងបញ្ចប់ក្រមប្រតិបត្តិសម្រាប់ការងារជលផល នាចុងឆ្នាំ ២០០៧

រដ្ឋបាលជលផលបានខិតខំតាក់តែង "ក្រមប្រតិបត្តិសម្រាប់ការងារជលផលកម្ពុជា" ដែលបានជួយឧបត្ថម្ភដោយអង្គការស្បៀងអាហារនិងកសិកម្ម (FAO) ប៉ុន្តែស្ថានភាពនៃសេចក្តីព្រាងនេះនៅមិនទាន់បានផ្សព្វផ្សាយជូនសាធារណៈនៅឡើយ ។

ចំពោះមុខនៃកង្វះពត៌មានអំពីស្ថានភាពនៃក្រមប្រតិបត្តិនេះ អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលមានការងឿងឆ្ងល់អំពីវឌ្ឍនភាពសម្រេចបានដោយរដ្ឋបាលជលផល (FiA) ពាក់ព័ន្ធនឹងសកម្មភាពនេះ។ អង្គការមិនមែនរដ្ឋាភិបាលមានការបារម្ភថា "ក្រមប្រតិបត្តិ" នេះ នឹងគ្រាន់តែជាទម្រង់ឯកសារគោលនយោបាយមួយទៀតប៉ុណ្ណោះដែលត្រួតជាន់គ្នាជាមួយច្បាប់និងបទប្បញ្ញត្តិមានស្រាប់ជាច្រើនដែលមានលក្ខណៈដូចគ្នាជាមួយនឹងច្បាប់និងបទប្បញ្ញត្តិជលផលផ្សេងទៀត និង រួមចំណែកតិចតួចដល់ការកាត់បន្ថយភាពក្រីក្រ។

### សូចនាករ ១០.២: ធានាឱ្យរដ្ឋបាលជលផលមានហិរញ្ញប្បទានគ្រប់គ្រាន់

រដ្ឋបាលជលផល (FiA) បានខិតខំកែលម្អកិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល និង ស្ថាប័នម្ចាស់ជំនួយ ជាចំណែកមួយនៃយុទ្ធនាការស្វែងរកមូលនិធិបន្ថែមទៀតដើម្បីអនុវត្តផែនការ

របស់ខ្លួន។ របាយការណ៍វឌ្ឍនភាព JMI ឆ្នាំ ២០០៦ បង្ហាញថារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានផ្ញើលិខិតមួយនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦ ជូនក្រសួងពាក់ព័ន្ធ អភិបាលខេត្ត និង សហគមន៍ ម្ចាស់-ជំនួយដើម្បីដាក់បញ្ចូលវិស័យជលផលទៅក្នុងផែនការរបស់ខ្លួន។ រដ្ឋបាលជលផលបានពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជលផលដើម្បីគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និង កំពុងរង់ចាំការឯកភាពពីក្រុមការងារជលផល។ ការពិនិត្យមើលស្ថាប័នរដ្ឋបាលជលផលក៏ត្រូវបានធ្វើឡើងផងដែរជាកិច្ចប្រឹងប្រែងមួយចំណែកដើម្បីកែលម្អកិច្ចសហប្រតិបត្តិការផ្នែកស្ថាប័ននៅក្នុងនិងនៅក្រៅរដ្ឋបាលជលផល។ សកម្មភាពទាំងនេះបង្ហាញពីកិច្ចប្រឹងប្រែងកាន់តែច្រើនឡើងនៅក្នុងការកែលម្អកិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលនៅក្នុងចំណោមស្ថាប័នរាជរដ្ឋាភិបាល។

ទោះជាយ៉ាងណាក្តី កិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលរបស់រដ្ឋបាលជលផលនៅតែបន្តប្រមូលផ្តុំ "អំណាច" និង "អាជ្ញា" របស់រដ្ឋបាលជលផល។ ម្ចាស់ជំនួយត្រូវបានចាត់ទុកថាជាដៃគូដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការដ៏រឹងមាំ ដោយសារម្ចាស់ជំនួយផ្តល់ហិរញ្ញប្បទានដល់កម្មវិធីរបស់ខ្លួនជាផ្នែកមួយនៃការផ្តល់អំណាចដល់រដ្ឋបាលជលផល។ ឧទាហរណ៍ អង្គការ DFID និង DANIDA គឺជាដៃគូសហប្រតិបត្តិការជាយូរមកហើយជាមួយរដ្ឋបាលជលផល។ រដ្ឋបាលជលផលបានទទួលមូលនិធិដើម្បីអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់រដ្ឋបាលជលផល ពីអង្គការ DFID/DANIDA សម្រាប់ឆ្នាំ ២០០៦ និង ផែនការអនាគត។ លើសពីនេះទៀតគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងវិស័យជលផលត្រូវបានតាក់តែងឡើងស្របតាម គោលនយោ-បាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅក្នុងវិស័យ កសិកម្ម ដោយមានការគាំទ្រមូលនិធិពីម្ចាស់ជំនួយ។ កិច្ចសហប្រតិបត្តិការក្នុងទម្រង់នេះបណ្តាលឱ្យមានអ្នកពិគ្រោះការងារបរទេសកាន់តែច្រើនដែលផ្តល់សេវាពិគ្រោះយោបល់ដើម្បីជួយរដ្ឋបាលជលផល ដែលជាហេតុបន្សល់ទុកសមត្ថភាពដ៏មានកម្រិតនៅក្នុងរដ្ឋបាលជលផល។

អង្គការក្រៅរដ្ឋាភិបាល និង សង្គមស៊ីវិលយល់ឃើញថាបញ្ហាសហប្រតិបត្តិការ និង សម្របសម្រួល គឺជា "បញ្ហារឹងប៉ឹង" មួយ និងមិនឃើញមានវឌ្ឍនភាពដែលសម្រេចបានដោយរដ្ឋបាលជលផលឡើយ ដោយសារកិច្ចសហប្រតិបត្តិការខាងស្ថាប័ននាពេលបច្ចុប្បន្ននេះគឺនៅដដែលដូចគ្នានឹងកាលពីប្រាំឆ្នាំមុនអញ្ចឹង។ តាមពិត កិច្ចសហប្រតិបត្តិការរបស់រដ្ឋបាលជលផលជាមួយស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត គឺអាស្រ័យលើកម្រិតនៃលទ្ធភាពដែលរដ្ឋបាលជលផលអាចរក្សា "អាជ្ញា" ឬ "អំណាច" របស់ខ្លួនលើតំបន់នេសាទ។ ហេតុនេះ កិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ស្ថាប័នរាជរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ នឹងបរិស្ថាន ហាក់បីដូចជាមានលក្ខណៈមិនគ្រប់គ្រាន់ឡើយ។ ប្រការនេះគឺមានលក្ខណៈពិតចំពោះគម្រោងមុខរបរប្រកបដោយនិរន្តរភាពនៅតំបន់ទន្លេសាប (TSSLP) នៅពេលដែលគម្រោងនេះត្រូវបានប្រតិបត្តិដោយក្រសួងមហាផ្ទៃ ហើយរដ្ឋ-បាលជលផលគឺជាដៃគូសហប្រតិបត្តិការ។ ដោយសារប្រការនេះ បុគ្គលិកកម្រិតទាបបំផុតនៃរដ្ឋបាលជលផល

ចាត់ទុកក្រុមប្រឹក្សាឃុំដែលអនុវត្តគម្រោង TSSLP ថាជាការគម្រាមកំហែងចំពោះអាជ្ញា និង អំណាចរបស់ពួកគេនៅក្នុងតំបន់នោះ។

១០.៣ ម្ចាស់ជំនួយផ្តល់ហិរញ្ញប្បទានដល់សកម្មភាពរបស់រដ្ឋបាលជលផលក្រោមក្របខ័ណ្ឌនៃ "យុទ្ធសាស្ត្រធ្វើសុខដុមនីយកម្មម្ចាស់ជំនួយ"។ ក្រុមការងារបច្ចេកទេសម្ចាស់ជំនួយ (DTWG) ដើរតួនាទីជា សេនាធិការរបស់ប្រទេសម្ចាស់ជំនួយដើម្បីផ្តល់ការយល់ព្រមដល់ការធ្វើផែនការ គណនេយ្យ និង ប្រព័ន្ធតាមដានរបស់រដ្ឋបាលជលផល។ ក្រុមការងារបច្ចេកទេសម្ចាស់ជំនួយបានធ្វើសុខដុមនីយកម្មលើ ការជួយគាំទ្ររបស់ម្ចាស់ជំនួយដល់រដ្ឋបាលជលផល ហើយការងារនេះគឺជាសកម្មភាពជាប់លាប់មួយ។

ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាល និង សហគមន៍នានាមើលឃើញថាសកម្មភាពនេះគឺជាការរួមចំណែកមិនសំខាន់មួយដល់ការអនុវត្តន៍មុខរបរ និង ការកាត់បន្ថយភាពក្រីក្រទេ។ ផ្ទុយទៅវិញ វាបម្រើឱ្យការធ្វើមជ្ឈការលើការគ្រប់គ្រងជលផលទៅវិញទេ។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលបារម្ភថាសកម្មភាពបែបនេះដែលធ្វើដោយរដ្ឋបាលជលផល គឺមិនសូវមានការតាមដានទេដោយសារកង្វះពត៌មានអំពីសកម្មភាពនានារបស់រដ្ឋបាលជលផល។ ម្យ៉ាងទៀត DTWG ក៏ស្ថិតក្រោមអធិបតីភាពរបស់រដ្ឋបាលជលផលដែរ ដូច្នេះសេចក្តីសម្រេចចិត្តភាគច្រើនដែលធ្វើដោយ DTWG គឺទទួលឥទ្ធិពលពីផលប្រយោជន៍របស់រដ្ឋបាលជលផល។ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ ពុំសូវមានឥទ្ធិពលទៅនៅក្នុង DTWG ហេតុនេះផលប្រយោជន៍ និង សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្រីក្រពុំត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការជលផលឡើយ។

**iii) អនុសាសន៍**

១០.១. អង្គការក្រៅរដ្ឋាភិបាល និង សហគមន៍ជលផលនៅមូលដ្ឋានសូមអំពាវនាវសុំឱ្យរដ្ឋបាលជលផល និង FAO ពិគ្រោះយោបល់ជាមួយអង្គការក្រៅរដ្ឋាភិបាលនិងសហគមន៍ នៅក្នុងការអភិវឌ្ឍន៍ក្រមប្រតិបត្តិកម្ពុជាសម្រាប់ការងារជលផល។ ម្ចាស់ជំនួយគប្បីធានាឱ្យបានថាក្រមប្រតិបត្តិនេះបម្រើផលប្រយោជន៍របស់សហគមន៍ទាំងឡាយនៅក្នុងមូលដ្ឋាន ជាជាងស្ថាប័នដែលធ្វើការងារនោះ។ អង្គការក្រៅរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ចេញព័ត៌មានអំពីក្រមប្រតិបត្តិនេះជូនដល់សាធារណៈឱ្យបានកាន់តែទៀងទាត់។

១០.២. អង្គការក្រៅរដ្ឋាភិបាល និង សង្គមស៊ីវិលសូមអំពាវនាវដល់ប្រទេសម្ចាស់ជំនួយសូមឱ្យពិចារណាឱ្យមានការចូលរួមបន្ថែមទៀតរបស់អង្គការក្រៅរដ្ឋាភិបាល និង សង្គមស៊ីវិលនៅក្នុងកម្មវិធីជលផលដែលផ្តល់ហិរញ្ញប្បទានដោយប្រទេសម្ចាស់ជំនួយ ក៏ដូចជាកម្មវិធីផ្សេងទៀតដែរ។ ផែនការនិងគោលនយោបាយជលផលជាច្រើន ត្រូវបានរៀបចំឡើងដោយមិនគិតគូរដល់ចំណេះដឹងនិងផលប្រយោជន៍របស់សហគមន៍នៅមូលដ្ឋានឡើយ។ ហេតុនេះ អង្គការក្រៅរដ្ឋាភិបាល និង សង្គមស៊ីវិលសូមស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជា និង ប្រទេសម្ចាស់ជំនួយ ពាក់ព័ន្ធអង្គការក្រៅរដ្ឋាភិបាល និង សហគមន៍នៅមូលដ្ឋានបន្ថែមទៀតនៅក្នុងការពិគ្រោះយោបល់លើផែនការនិងគោលនយោបាយទាំងនេះដែលមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។

១០.៣. អង្គការក្រៅរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលសូមអំពាវនាវសូមឱ្យរាជរដ្ឋាភិបាលកម្ពុជាកែឡើងវិញនូវ "សកម្មភាពចាំបាច់" ដែលមានបង្ហាញនៅក្នុង JMI នេះ ប្រសិនបើវិស័យជលផលមានបំណងរួមចំណែកដល់ការលើកស្ទួយជីវភាព និង ការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍ជលផល ដោយសារ "សកម្មភាពចាំបាច់" បច្ចុប្បន្ននេះ គិតគូរដល់ផលប្រយោជន៍របស់រដ្ឋបាលជលផល ជាជាងការកាត់បន្ថយភាពក្រីក្រ ។

# ប្រព័ន្ធច្បាប់ និង តុលាការ

**i) សូចនាករតាមដានរួម**

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវ |
|---|---|---|
| ១៦- រៀបចំប្រព័ន្ធច្បាប់ និងតុលាការឱ្យដំណើរការល្អ ប្រកបដោយគណនេយ្យភាព និងតម្លាភាពដែលការពារសិទ្ធិបុគ្គល ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ | ១- គោលបំណងទី២ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ : បញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ និងអនុមតិច្បាប់សំខាន់ៗដែលនៅសេសសល់ ( ក្រមស្តីពីនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រម ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ និងច្បាប់ស្តីពី ការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម) ។<br>២- គោលបំណងទី២និង៧នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការៈ ពិនិត្យបញ្ចប់នូវគោលការណ៍ណែនាំសម្រាប់ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ដោយផ្អែកលើបទពិសោធន៍កន្លងមក ។ គោលការណ៍ណែនាំនេះនឹងលើក អំពីតម្រូវការខាងកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់កសាងសមត្ថភាព និងសម្រាប់ពង្រឹងភាពម្ចាស់ការរបស់អង្គភាពរៀបចំច្បាប់នៃក្រសួងពាក់ព័ន្ធ ។<br>៣- គោលបំណងទី៤និង៧នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការៈ ការបណ្តុះបណ្តាល និងការជ្រើសរើសប្រកបដោយតម្លាភាពនូវមន្ត្រីបំរើឱ្យផ្នែកតុលាការ និងច្បាប់ដើម្បីកែលំអការផ្តល់សេវាតុលាការ និងកិច្ចដំណើរការរបស់តុលាការ ។ | ក្រសួងយុត្តិធម៌ |

**ii) វឌ្ឍនភាពដែលបានតាមដាន**

**សូចនាករ ១៦.១: បញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ និងអនុមតិច្បាប់សំខាន់ៗដែលនៅ សេសសល់**

អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យកំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ សូមស្វាគមន៍ចំពោះការអនុម័ត និងការដាក់ឱ្យប្រើប្រាស់**ក្រមនីតិវិធីព្រហ្មទណ្ឌ** និង **ក្រមនីតិវិធីរដ្ឋប្បវេណី** នាពេលថ្មីៗ និងសូមសរសើររាជរដ្ឋាភិបាលចំពោះការសម្រេចបានស្នាដៃដ៏ល្អទាំងនេះ ។ ទោះបីជាយ៉ាងដូចនេះក្តី ការផ្សព្វផ្សាយ និងការលើកកំពស់ការយល់ដឹងអំពីក្រមទាំងនេះនៅមិនទាន់បានទូលំទូលាយនៅឡើយ ។ រីឯការរីកចំរើនលើ **សេចក្តីព្រាងច្បាប់ព្រហ្មទណ្ឌ** មានការយឺតយ៉ាវបំផុត ។ សេចក្តីព្រាងច្បាប់នេះមិនទាន់អនុម័តដោយគណៈរដ្ឋមន្ត្រីនៅឡើយទេ ។ វានៅតែស្ថិតក្រោមការពិនិត្យឡើងវិញដោយក្រសួង យុត្តិធម៌ដដែលទាក់ទងនឹងបទល្មើសបន្ថែម ។

**សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម** បច្ចុប្បន្នកំពុងស្ថិតនៅការិយាល័យរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងកំពុងត្រៀមដាក់ជូនការពិភាក្សានៅក្នុងការប្រជុំអន្តរក្រសួង ។ អង្គការមិនមែនរដ្ឋាភិបាលរីករាយចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការងារឱ្យបោះជំហានទៅមុខ ។

**សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ** បច្ចុប្បន្នកំពុងស្ថិតក្រោមការពិនិត្យឡើងវិញរបស់ក្រសួងយុត្តិធម៌។ ក្រសួងយុត្តិធម៌កំពុងរង់ចាំយោបល់ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមុនពេលដាក់សេចក្តីព្រាងច្បាប់នេះជូនទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីសុំយោបល់ និងការពិភាក្សាបន្ថែម។

**សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (SCM)** នៅតែស្ថិតនៅក្រសួងយុត្តិធម៌នៅឡើយ។ សំរាប់សេចក្តីព្រាងច្បាប់នេះរាជរដ្ឋាភិបាលហាក់ដូចជាគ្មានឆន្ទៈច្បាស់លាស់ក្នុងការជំរុញច្បាប់នេះទៅមុខសំរាប់ការអនុម័តឱ្យបានឆាប់ឡើយ។ មន្ត្រីរដ្ឋាភិបាលម្នាក់បានបង្ហើបឱ្យដឹងថាការជំរុញឱ្យមានការអនុម័តសេចក្តីព្រាងច្បាប់នេះ គឺផ្អែកលើឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។ ចំពោះការដកហូតមន្ត្រីតុលាការចេញពីតំណែងនាពេលថ្មីៗនេះ ឧទាហរណ៍ ការដក លោកស្រី លី វ៉ូចលេង អតីតប្រធានសាលាឧទ្ធរណ៍ ឱ្យទៅបំរើការនៅក្រសួងយុត្តិធម៌ និងដាក់ជំនួសដោយលោក យូ ប៊ុនឡេង បានលាតត្រដាងអោយឃើញថារាជរដ្ឋាភិបាលពេញចិត្តចំពោះសកម្មភាពរបស់ខ្លួន ហើយចាត់ទុកថាសកម្មភាពរបស់ពួកគេគឺជាផ្នែកមួយនៃកំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ។ ប្រការនេះបង្ហាញឱ្យឃើញថាការកែទំរង់ប្រព័ន្ធតុលាការគឺជាការបោះជំហានដ៏ល្អមួយសំរាប់ការកែទំរង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ អង្គការមិនមែនរដ្ឋាភិ-បាលធ្វើការលើប្រព័ន្ធច្បាប់និងតុលាការរីករាយនឹងសកម្មភាពនេះ ក៏ប៉ុន្តែមានការព្រួយបារម្ភពីការពន្យាពេលក្នុងការអនុម័តពង្រាងច្បាប់ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**សូចនាករ ១៦.២: ពិនិត្យនិងបញ្ចប់គោលការណ៍ណែនាំសម្រាប់ដំណើរការរៀបចំសេចក្តីព្រាងច្បាប់**

គោលការណ៍បច្ចុប្បន្នស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រីនៅឡើយ ហើយកំពុងត្រូវបានពិនិត្យឡើងវិញដោយអង្គភាពកំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ អង្គភាពកំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការនឹងដាក់គោលការណ៍ណែនាំនេះជូនទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិភាក្សា និង អនុម័ត ប៉ុន្តែរហូតមកដល់ពេលនេះពុំទាន់មានកាលបរិច្ឆេទច្បាស់លាស់សំរាប់ទីស្តីការគណៈរដ្ឋមន្ត្រីក្នុងការប្រជុំ និងអនុម័តគោលការណ៍ណែនាំនេះនៅឡើយទេ។

**សូចនាករ ១៦.៣: ការបណ្តុះបណ្តាល និងការជ្រើសរើសមន្ត្រីតុលាការប្រកបដោយតម្លាភាព** ជាផ្នែកមួយនៃការបណ្តុះបណ្តាលនិងការជ្រើសរើសមន្ត្រីតុលាការប្រកបដោយតម្លាភាព រាជរដ្ឋាភិបាលបានបង្កើតសាលាភូមិន្ទតុលាការ និងបានផ្តល់ឱកាសដល់អ្នកដែលបានទទួល ការអប់រំផ្នែកច្បាប់ឱ្យបន្តជំនាញ/ការបណ្តុះបណ្តាលឯកទេសរបស់ពួកគេនៅសាលានេះដើម្បីធ្វើជាចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីតុលាការដទៃទៀត។ សាលានេះទទួលសិស្សចំនួន៧០ នាក់ក្នុងមួយឆ្នាំសំរាប់ការបណ្តុះបណ្តាលជំនាញ/ឯកទេសជាក់លាក់ស្តីពីអាជីពផ្នែកតុលាការរបស់ពួកគេ។ សិស្សដែលបានបញ្ចប់ការសិក្សានៅសាលានេះនឹងក្លាយជាជនគោលដៅសំរាប់ជ្រើសរើសឱ្យចូលបំរើការផ្នែកសេវាតុលាការ។ រហូតមកដល់ពេលនេះពុំទាន់មានការអនុវត្តន៍ជាក់ស្តែងស្តីពីការជ្រើសរើសអ្នកប្រកបវិជ្ជាជីវៈតុលាការឱ្យចូលបំរើការងារនៅក្នុងសេវាតុលាការនៅឡើយទេ។

### iii) អនុសាសន៍

**ពាក់ព័ន្ធនឹងសូចនាករ ១៦.១ អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់ជាអនុសាសន៍ដូចតទៅ:**

- រដ្ឋាភិបាលត្រូវបន្តបង្កើនការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយថែមទៀតអំពី ***ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី*** ដើម្បីធានាថាសាធារណជនទូទៅ និងមន្ត្រីអនុវត្តច្បាប់កម្ពុជាជាពិសេស មានការយល់ដឹងអំពីច្បាប់សំខាន់ៗទាំងនេះនៅក្នុងប្រទេស ។
- រដ្ឋាភិបាលត្រូវផ្តល់ការបណ្តុះបណ្តាលជាបន្តដល់មន្ត្រីអនុវត្តច្បាប់ទាំងអស់ដើម្បីធានាថាពួកគេមានចំណេះដឹងជាមូលដ្ឋាន និងការយល់ដឹងអំពីច្បាប់ទាំងនេះដើម្បីឱ្យពួកគេអាចអនុវត្តច្បាប់សំខាន់ៗដែលទើបបានអនុម័តថ្មីៗប្រកបដោយប្រសិទ្ធភាព និងបានសមស្រប ។
- រដ្ឋាភិបាលត្រូវបង្កើនល្បឿននៃការអនុម័ត ***ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម*** *និង* ***ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ*** ដើម្បីធានានូវប្រសិទ្ធភាព ភាពមិនលំអៀង និងឯករាជ្យភាពរបស់តុលាការទូទាំងប្រទេស ។
- ដើម្បីធានានូវឯករាជ្យភាពក្នុងការប្រព្រឹត្តិទៅរបស់តុលាការ និងដើម្បីដាក់ទណ្ឌកម្មលើការប្រព្រឹត្តិខុសឆ្គងរបស់មន្ត្រីតុលាការ រដ្ឋាភិបាលត្រូវបង្កើនល្បឿនលើការអនុម័ត ***ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។***

**ពាក់ព័ន្ធនឹងសូចនាករ ១៦.២ អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់ជាអនុសាសន៍ថា**

- រដ្ឋាភិបាលត្រូវបង្កើនល្បឿនលើការអនុម័ត ***គោលការណ៍ណែនាំសំរាប់ដំណើរការធ្វើសេចក្តីព្រាងច្បាប់*** ដើម្បីឱ្យអង្គភាពច្បាប់នីមួយៗរបស់ក្រសួងទាំងអស់បានរៀបចំគោលការណ៍ណែនាំ ហើយពួកគេនឹងទទួលបានការកសាងសមត្ថភាពស្តីពីដំណើរការសមស្របសំរាប់ការធ្វើសេចក្តីព្រាងច្បាប់ ។

**ពាក់ព័ន្ធនឹងសូចនាករ ១៦.៣ អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់ជាអនុសាសន៍ថា**

- រដ្ឋាភិបាលត្រូវជួយសំរួល បន្តលើកទឹកចិត្ត និងបើកឱកាសកាន់តែទូលំទូលាយដល់អ្នកដែលបានទទួលការអប់រំផ្នែកច្បាប់ទាំងអស់ទាំងនៅតាមខេត្ត-ក្រុងនានា និងនៅទីក្រុងភ្នំពេញ ឱ្យមកបន្តការអប់រំអំពីជំនាញច្បាប់ និងតុលាការនៅសាលាភូមិន្ទវិជ្ជាជីវៈចៅក្រម ។
- ការប្រយុទ្ធប្រឆាំងរាល់ទំរង់នៃអំពើពុករលួយ ឬភាពមិនប្រក្រតីណាមួយដែលបានកើតឡើងក្នុងកំឡុងពេលជ្រើសរើសអ្នកដែលមានការអប់រំផ្នែកច្បាប់សំរាប់ការចូលរៀនបន្តនៅសាលាភូមិន្ទចៅក្រម ឬ ចូលបំរើការងារនៅក្នុងសេវាផ្នែកតុលាការ ។

# ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

**i) សូចនាករតាមដានរួម**

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវ |
|---|---|---|
| ១៧. ប្រយុទ្ធប្រឆាំងនឹង អំពើពុករលួយ | ១- រៀបចំបញ្ចប់ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹង អំពើពុករលួយ ស្របតាមបទដ្ឋានជាអន្តរជាតិ ។<br>២- រៀបចំផែនការសម្រាប់គ្រប់គ្រងការអនុវត្តន៍ច្បាប់ស្តីពីការ ប្រឆាំង នឹងអំពើពុករលួយ ។<br>៣- ផ្សព្វផ្សាយជាទៀងទាត់ ៦ខែម្តងព័ត៌មានស្តីពីករណីអំពើពុក រលួយ និងការផ្តន្ទាទោស ។<br>៤- រៀបចំក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ស្តីពីសិទ្ធិទទួល បាន ពត៌មាន ។ | ក្រសួងទំនាក់ទំនងរដ្ឋ សភា ព្រឹទ្ធសភា និងអធិការកិច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី |

**ii) វឌ្ឍនភាពដែលបានតាមដាន**

## សូចនាករ ១៧.១: រៀបចំបញ្ចប់ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹង អំពើពុករលួយ

ចាប់តាំងពីវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជារហូតមកដល់ពេលនេះ ពុំមានរបាយការណ៍ស្តីពីភាពរីកចំរើនណាមួយទាក់ទងនឹងសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយឡើយ ។ ឯកសារថ្មីបំផុតនៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលអង្គការសង្គមស៊ីវិលទទួលបានមានចុះកាលបរិច្ឆេទថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ (កាលបរិច្ឆេទត្រូវបានសរសេរដោយដៃ) ប៉ុន្តែអត្ថបទច្បាប់នេះដូចគ្នានឹងអត្ថបទដែលចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៦ យ៉ាងពិតប្រាកដ (លើកលែងតែថាអត្ថបទថ្មីនេះមានតារាងមាតិកា) ។ ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័តកាលពីដើមឆ្នាំនេះ ។ ការអនុម័តច្បាប់នេះគួរតែជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ពីព្រោះរាជរដ្ឋាភិបាលបានទទូចថាការអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌនេះ គឺជាល័ក្ខខ័ណ្ឌជាមុន សំរាប់ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ដោយសារតែមានតំរូវការក្នុងការធ្វើសុខុដុមនីយកម្មនូវច្បាប់ទាំងពីរ ។ ក៏ប៉ុន្តែពេលនោះ ស្រាប់តែលេចចេញនូវច្បាប់មួយទៀតដែលត្រូវការឱ្យមាន មុនច្បាប់ប្រឆាំងអំពើពុករលួយ ហើយបើតាមរាជរដ្ឋាភិបាល ច្បាប់នោះឯងគឺ ក្រមព្រហ្មទណ្ឌ ។ ទោះជាយ៉ាងនេះក្តី នៅតែមិនទាន់ច្បាស់លាស់នៅឡើយពីភាគីរាជរដ្ឋាភិបាល ថាតើមានច្បាប់ផ្សេងទៀតដែរឬទេ — ក្រៅពីក្រមព្រហ្មទណ្ឌ — ដែលតំរូវឱ្យមាន មុនការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ។ អាស្រ័យដោយរាជរដ្ឋាភិបាលនៅតែបន្តនិយាយដល់ "ច្បាប់ដែលពាក់ព័ន្ធ" ដោយមិនបានបញ្ជាក់ឱ្យបានច្បាស់ថាតើច្បាប់ណាមួយឱ្យពិតប្រាកដនោះ អង្គការសង្គមស៊ីវិលមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយយល់ឃើញថារាជរដ្ឋាភិបាលពុំមានភាពម៉ឺងម៉ាត់ប្រាកដប្រជានឹងដោះស្រាយបញ្ហានេះឡើយ ។ សង្គមស៊ីវិលមានការព្រួយបារម្ភទៀតថា គ្រាន់តែក្រមព្រហ្មទណ្ឌមួយត្រូវចំណាយពេលច្រើនណាស់ទៅហើយ មុននឹងទៅដល់ការអនុម័ត ដូច្នេះច្បាប់ផ្សេងៗទៀត អាចនឹងលើកឡើងជាលេសសំរាប់ការពន្យារពេលបន្ថែមទៀត ។

ទាក់ទងទៅនឹងខ្លឹមសារ ដូចបានពោលខាងលើរួចមកហើយដែរ ពុំមានការកែលម្អណាមួយលើអត្ថបទសេចក្តីព្រាងច្បាប់ចុះថ្ងៃទី ២៩ខែ កញ្ញា ឆ្នាំ២០០៦ ឬអត្ថបទចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ដោយធ្វើការពិចារណាដាក់បញ្ចូលនូវយោបល់ និងមតិរបស់អង្គការសង្គមស៊ីវិល នោះឡើយ ជាពិសេសទាក់ទងនឹងបញ្ហាសំខាន់ៗស្តីអំពីឯករាជ្យភាពរបស់ស្ថាប័នប្រឆាំងអំពើពុករលួយៈ តួនាទីផ្តល់យោបល់របស់ឧត្តមក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយនិងមុខងារប្រតិបត្តិរបស់អគ្គលេខាធិការដ្ឋាន និងថវិកាឯករាជ្យសំរាប់ស្ថាប័នប្រឆាំងអំពើពុករលួយ ការប្រកាសទ្រព្យសម្បត្តិ និងកិច្ចការពារសាក្សី/អ្នកប្តឹងរាយការណ៍ ជាដើម។

ទោះបីជាមានអ្នកតំណាងរាស្ត្រប៉ុន្មាននាក់មកពីគណបក្សកាន់អំណាច ត្រូវបានប្រព័ន្ធផ្សព្វផ្សាយដកស្រង់សំដីដែលបានមានប្រសាសន៍ថា ពួកលោករំពឹងថារាជរដ្ឋាភិបាលនឹងដាក់ជូនរដ្ឋសភានូវសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ក្នុងពេលឆាប់ៗនេះក៏ដោយ ក៏គ្មានសញ្ញាបញ្ជាក់ជាផ្លូវការថាសេចក្តីព្រាងច្បាប់នេះនឹងអាចរួចរាល់សំរាប់ការពិភាក្សារបស់រដ្ឋសភាឡើយ។ ការខកខានមិនបានកំណត់ពេលច្បាស់លាស់សម្រាប់រាជរដ្ឋាភិបាលបញ្ចប់សេចក្តីព្រាងច្បាប់នេះ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា និងកង្វះការពន្យល់ច្បាស់លាស់ថា តើច្បាប់ពាក់ព័ន្ធអ្វីខ្លះ ដែលត្រូវរង់ចាំឱ្យអនុម័តជាមុនសិននោះ បានធ្វើឱ្យសង្គមស៊ីវិលមានការព្រួយបារម្ភកាន់តែខ្លាំងឡើងថារាជរដ្ឋាភិបាលគ្មានឆន្ទៈនយោបាយពិតប្រាកដ ក្នុងការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ និងមិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការដោះស្រាយអំពើពុករលួយឡើយ។

**សូចនាករ ១៧.២: រៀបចំផែនការសម្រាប់គ្រប់គ្រងការអនុវត្តន៍ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ**

សង្គមស៊ីវិលសូមរំលឹកឡើងវិញថាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (MoNASRI) ដោយមានជំនួយពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានផ្តល់អ្នកជំនាញការពីរនាក់មកពីប្រទេសសិង្ហបុរី កាលពីខែមីនា ឆ្នាំ២០០៧ ឱ្យជួយធ្វើសេចក្តីព្រាងផែនការសម្រាប់គ្រប់គ្រងការអនុវត្តន៍ច្បាប់ប្រឆាំងអំពើពុករលួយ។ ការងារនេះ រួមមានការរៀបចំជាជំហានៗក្នុងការបង្កើតស្ថាប័នប្រឆាំងអំពើពុករលួយ (ACB) ក្នុងនោះរួមមានទាំងការធ្វើផែនការសំរាប់ប្រតិបត្តិការ ការគាំទ្រដល់បុគ្គលិករបស់ ស្ថាប័នប្រឆាំងអំពើពុករលួយ និងការបណ្តុះបណ្តាលសំរាប់ពួកគេ ការសិក្សាលំអិតអំពីសម្ភារៈ-ឧបករណ៍ការិយាល័យ ដែលចាំបាច់ និងការរៀបចំថវិកាសំរាប់ការបង្កើតឡើងដំបូង និងចំណាយប្រតិបត្តិការជារួម។ ផែនការនេះក៏ពិពណ៌នាផងដែរ អំពីយន្តការដែលត្រូវរៀបចំឡើងដើម្បីអនុវត្តវិធានការប្រឆាំងអំពើពុករលួយដែលមានបីផ្នែក (អប់រំផ្សព្វផ្សាយ ការបង្ការ និងការស៊ើបអង្កេត)។ ការងារនេះ បង្ហាញពីភាពរីកចំរើនរបស់រាជរដ្ឋាភិបាល ទោះបីជាមានការយឺតយ៉ាវក៏ដោយ ហើយសង្គមស៊ីវិលសូមកោតសរសើរចំពោះការប្រឹងប្រែងនេះ។ តែទោះជាយ៉ាងណាក៏ដោយ សេចក្តីព្រាងផែនការអនុវត្តន៍នេះមិនទាន់បានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីនៅឡើយទេ។ តាមប្រភពដែលអាចយកជាការបាននៃក្រសួងនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សេចក្តីព្រាងផែនការអនុវត្តន៍នេះទំនងជានឹងត្រូវ

ដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីនៅពេលណាមួយ មុនការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរដ្ឋាភិបាល-ម្ចាស់ជំនួយ លើកក្រោយនៅក្នុងខែតុលាខាងមុខនេះ។

**សូចនាករ ១៧.៣: ផ្សព្វផ្សាយជាទៀងទាត់ ៦ខែម្តងព័ត៌មានស្តីពីករណីអំពើពុករលួយ និងការផ្តន្ទាទោស**

សង្គមស៊ីវិលសូមសរសើររាជរដ្ឋាភិបាលចំពោះការខិតខំ ប៉ុនប៉ងរាយការណ៍អំពីករណីអំពើពុករលួយដែលមានការពាក់ព័ន្ធជាមួយមន្ត្រីសាធារណៈ។ ករណីថ្មីៗបំផុតដែលពាក់ព័ន្ធជាមួយអតីតប្រធានតុលាការកំពូល និងមន្ត្រីថ្នាក់ខេត្តដែលត្រូវបានដកចេញពីតំណែងដោយសារការពាក់ព័ន្ធជាមួយអំពើពុករលួយ ប្រសិនបើករណីនេះជាករណីពិតនោះ វាគឺជាជំហានជាវិជ្ជមានមួយឈានទៅរកការលើកកំពស់គណនេយ្យភាព និងតម្លាភាពរបស់រាជរដ្ឋាភិបាល ហើយដូច្នេះរាជរដ្ឋាភិបាលសមនឹងទទួលបានការកោតសរសើរ។

សង្គមស៊ីវិលក៏សូមស្វាគមន៍ផងដែរចំពោះការបង្ក្រាបអ្នកជួញគ្រឿងញៀនដែលបានរាយការណ៍ឱ្យដឹងនាពេលថ្មីៗនេះ ពីព្រោះអង្គការមិនមែនរដ្ឋាភិបាលមានជំនឿថាអំពើពុករលួយប្រាកដជាមានការពាក់ព័ន្ធជាមួយការជួញដូរគ្រឿងញៀន។ ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាលសង្កេតឃើញថាការរាយការណ៍នេះ នៅមិនទាន់ធ្វើឡើងជាលក្ខណៈប្រព័ន្ធ និងមានរចនាសម្ព័ន្ធត្រឹមត្រូវនៅឡើយ។ ម្យ៉ាងវិញទៀត នៅក្នុងករណីមួយចំនួននៃករណីទាំងនេះ ការរាយការណ៍គ្រាន់តែធ្វើឡើងលើផ្នែកណាមួយតែប៉ុណ្ណោះ តែគ្មានការតាមដានគ្រប់គ្រាន់។ អង្គការមិនមែនរដ្ឋាភិបាលក៏បានសង្កេតឃើញផងដែរថា ករណីនៃអំពើពុករលួយនិងការដាក់ទណ្ឌកម្មដែលបានរាយការណ៍នៅតែមានលក្ខណៈជ្រើសរើស។ ដូច្នេះ ការតាមដានលើករណីទាំងនោះមិនអាចធ្វើទៅបានឡើយ ហើយក៏ពុំមានផលប៉ះពាល់ខ្លាំងទៅលើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដែរ។ ដូច្នេះ អង្គការមិនមែនរដ្ឋាភិបាលអាចនិយាយបានថាសូចនាករនេះមិនបានសម្រេចពេញលេញទេ។

**សូចនាករ ១៧.៤: រៀបចំក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ស្តីពីសិទ្ធិទទួលបានពតិមាន**

អង្គការមិនមែនរដ្ឋាភិបាលសូមសំដែងនូវការកោតសរសើរចំពោះក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (MoNASRI) របស់រាជរដ្ឋាភិបាល ដែលបានចាត់វិធានការរៀបចំសេចក្តីព្រាងឯកសារគោលនយោបាយស្តីពីសិទ្ធិទទួលបានពតិមាន ដែលជាគ្រឹះសម្រាប់ការធ្វើច្បាប់ស្តីពីសិទ្ធិទទួលពតិមាននៅពេលអនាគត។ ទោះបីជាមានការយឺតយ៉ាវមួយរយៈមុនក៏ដោយ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចកំពុងបោះជំហានយ៉ាងមុតមាំ បន្ទាប់ពីការប្រជុំវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ក្នុងការរៀបចំក្របខ័ណ្ឌគោលនយោបាយមួយស្តីពីសិទ្ធិទទួលពតិមាន។ ដោយមានជំនួយបច្ចេកទេសពីអ្នកជំនាញផ្នែកសិទ្ធិទទួលពតិមានលំដាប់ពិភពលោក និងទីប្រឹក្សាក្នុងស្រុកម្នាក់ ដែលត្រូវបានឧត្ថម្ភទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ជំនួយអន្តរជាតិ (USAID) តាមរយៈអង្គការផេកកម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ពេលនេះបានបញ្ចប់សេចក្តីព្រាងគោលនយោបាយនោះហើយ ហើយបានឱ្យដឹងថានឹងដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីនៅពេលណាមួយមុនការប្រជុំគណៈកម្មាធិការរាជរដ្ឋាភិបាល-ម្ចាស់ជំនួយលើក ក្រោយនៅក្នុងខែតុលានេះ។

អង្គការមិនមែនរដ្ឋាភិបាលក៏សូមសរសើររាជរដ្ឋាភិបាល/ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ផងដែរដែលបានអនុញ្ញាតឱ្យភាគីពាក់ព័ន្ធជាច្រើន ជាពិសេសតំណាងអង្គការមិនមែនរដ្ឋាភិបាល ចំនួនពីររូបនៃក្រុមការងារស្តីពីសិទ្ធិទទួលបានព័ត៌មាន ឱ្យចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីព្រាងគោលនយោបាយនេះតាមរយៈការចែករំលែកពត៌មាន និងគំនិតជាមួយក្រុមការងារធ្វើសេចក្តីព្រាងគោលនយោបាយ របស់រាជរដ្ឋាភិបាល លើក្របខ័ណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលបានពត៌មាននេះ។

**iii) អនុសាសន៍**

**សូចនាករ ១៧.១: រៀបចំបញ្ចប់ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹង អំពើពុករលួយ**

- ការប្រឆាំងអំពើពុករលួយបានក្លាយជាបញ្ហាពិភពលោកកាន់តែខ្លាំងឡើងៗ។ ការដែលរាជរដ្ឋាភិបាលបានចូលរួមជាមួយប្រទេសនៅអាស៊ីអាគ្នេយ៍ ក្នុងការចុះហត្ថលេខាលើកតិកាសញ្ញាប្រឆាំងអំពើពុករលួយនាពេលថ្មីៗនេះ ក្នុងគោលបំណងទប់ស្កាត់និងប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងតំបន់ និងការដែលរាជរដ្ឋាភិបាលកំពុងត្រៀមខ្លួនធ្វើជាហត្ថលេខីចំពោះអនុសញ្ញាស្តីពីការប្រឆាំងអំពើពុករលួយរបស់អង្គការសហប្រជាជាតិ នោះត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅដោយសង្គមស៊ីវិល។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលគួរតែឈានមួយជំហានទៅមុខទៀតពីការនិយាយទៅរកការធ្វើសកម្មភាពជាក់ស្តែង ដោយការបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដោយគ្មានការអូសបន្លាយពេលវេលាតទៅទៀត។ អង្គការមិនមែនរដ្ឋាភិបាលមើលឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាច្បាប់តែមួយគត់ដែលត្រូវដំណើរការជាមួយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ហើយដោយហេតុថាក្រមនេះត្រូវបានអនុម័តនិងប្រកាសឱ្យប្រើរួចហើយនោះ មិនត្រូវមានហេតុផលណាមួយផ្សេងទៀត សម្រាប់ពន្យារពេលលើច្បាប់ប្រឆាំងអំពើពុករលួយតទៅទៀតឡើយ។ អំពើពុករលួយគឺជាបញ្ហាអន្តរវិស័យ ដូច្នេះវាមានការពាក់ព័ន្ធជាមួយអ្វីៗគ្រប់យ៉ាង។ ដូច្នេះការប៉ុនប៉ងណាមួយដើម្បីឱ្យវាត្រូវគ្នាជាមួយច្បាប់ផ្សេងៗទៀតជាមុនសិន មានន័យថា "មិនអាចទៅដល់ទីណាឡើយ"។ វាគួរតែបញ្ច្រាសមកវិញ ពោលគឺៈ ច្បាប់ប្រឆាំងអំពើពុករលួយត្រូវធ្វើមុន ហើយច្បាប់ផ្សេងទៀត ធ្វើតាមក្រោយ។
- ជាមួយគ្នានេះដែរ សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយត្រូវការពិនិត្យឡើងវិញនិងកែលំអ ជាពិសេសទាក់ទិននឹងបញ្ហាសំខាន់ៗដែលនៅសេសសល់បីចំណុចដែលបានពោលខាងលើ ដើម្បីធានាថាច្បាប់នេះបំពេញតាមស្តង់ដារអន្តរជាតិ មុននឹងដាក់ជូនរដ្ឋសភាពិភាក្សានិងអនុម័ត។ ការខកខានមិនបានគោរពតាមស្តង់ដារអន្តរជាតិ មានន័យថាសូចនាករនេះមិនបានសម្រេចទេ និងថាប្រសិនបើច្បាប់នេះត្រូវបានអនុម័ត សង្គមស៊ីវិលជាពិសេស នឹងមិនអាចទទួលយកបានថាជាឧបករណ៍មួយដែលមានប្រសិទ្ធភាព អាចប្រើប្រាស់ប្រឆាំងអំពើពុករលួយបានឡើយ។

**សូចនាករ ១៧.២: រៀបចំផែនការសម្រាប់គ្រប់គ្រងការអនុវត្តន៍ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ**

- រាជរដ្ឋាភិបាល/ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច គួរតែបន្តជំរុញការងារលើសេចក្តីព្រាងផែនការអនុវត្តន៍ដើម្បីសម្រេចបាននូវសូចនាករនេះ និងដើម្បីធានាថាផែនការនេះត្រូវបានរៀបចំឡើងដោយជាក់លាក់ក្នុងនាមជាឧបករណ៍សម្រាប់ការពង្រឹង និងការអនុវត្តន៍ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលស្របតាមស្តង់ដារអន្តរជាតិ នៅពេលដែលច្បាប់នេះត្រូវបានអនុម័ត ពោលគឺមិនមែនជាអ្វីមួយដែលបានត្រឹមតែធ្វើឱ្យប៉ះពាល់ដល់គោលការណ៍នៃការអនុវត្តន៍ល្អជាអន្តរជាតិនៃការប្រឆាំងអំពើពុករលួយ នោះឡើយ ។

**សូចនាករ ១៧.៣៖ ផ្សព្វផ្សាយជាទៀងទាត់ ៦ខែម្តងព័ត៌មានស្តីពីករណីអំពើពុករលួយ និងការផ្តន្ទាទោស**

- រាជរដ្ឋាភិបាលកម្ពុជាគួរតែកែលំអយន្តការរាយការណ៍របស់ខ្លួន ដោយការបង្កើតនូវឧបករណ៍រាយការណ៍ដែលមានលក្ខណៈជាប្រព័ន្ធមួយ សំរាប់រាយការណ៍ឱ្យបានទៀងទាត់ជូនរដ្ឋសភានិងសាធារណជន អំពីភាពរីកចំរើនក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ទិន្នន័យដែលត្រូវរាយការណ៍តាមរយៈយន្តការពត៌មានសាធារណៈគួររាប់បញ្ចូល (ប៉ុន្តែមិនកំណត់ត្រឹមនេះ)៖ ចំនួននៃការស៊ើបអង្កេតលើការប្រព្រឹត្តអំពើពុករលួយដែលបានប្រព្រឹត្តឡើង ចំនួននៃការចាប់ខ្លួន ចំនួននៃសកម្មភាពរដ្ឋបាលដែលបានធ្វើ ចំនួននៃការដាក់ទោស និង/ឬការដកហូតតំណែងផ្នែករដ្ឋបាល រយៈពេលនៃការព្យួរការងារផ្នែករដ្ឋបាល ឬការកាត់ទោសជនល្មើសដែលមានទោស និងចំនួនប៉ាន់ប្រមាណនៃផលប៉ះពាល់ផ្នែករូបិយវត្ថុលើបទល្មើសដែលបានប្រព្រឹត្ត ។

**សូចនាករ ១៧.៤៖ រៀបចំក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ស្តីពីសិទ្ធិទទួលបានពត៌មាន**

- ទន្ទឹមនឹងការសំដែងការអបអរសាទរចំពោះក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានបន្តជំរុញការងារលើការធ្វើសេចក្តីព្រាងឯកសារគោលនយោបាយស្តីពីសិទ្ធិទទួលបានពត៌មាន អង្គការមិនមែន រដ្ឋាភិបាលសូមផ្តល់អនុសាសន៍ឱ្យរាជរដ្ឋាភិបាលបញ្ចប់ការពិនិត្យផ្ទៃក្នុងលើឯកសារគោលនយោបាយនេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ហើយប្រែក្លាយឯកសារនេះឱ្យទៅជាច្បាប់ស្តីពីសិទ្ធិទទួលបានពត៌មានឱ្យបានមុនដំណាច់ឆ្នាំ២០០៨។

# វិមជ្ឈការ និង វិសហមជ្ឈការ

**i) សូចនាករតាមដានរួម**

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរាជរដ្ឋាភិបាលដែលទទួលខុសត្រូវ |
|---|---|---|
| ១៨. រៀបចំសម្រាប់អនុវត្តឱ្យបានពេញលេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា | ១. បន្តរៀបចំសេចក្តីព្រាងច្បាប់អង្គការស្តីពី ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ផ្តួចផ្តើមការពិគ្រោះយោបល់ទូលាយជាមួយភាគីពាក់ព័ន្ធ នៅក្នុងត្រីមាសទី ៤ ឆ្នាំ ២០០៧។ | គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) |
| | ២. រៀបចំកម្មវិធីជាតិដោយបញ្ជាក់ពីទម្រង់ការនិងធនធានសម្រាប់អនុវត្ត ដែលត្រូវចាប់ផ្តើមនៅក្នុងត្រីមាសទី ២ ឆ្នាំ ២០០៨។ | (គ.ជ.វ.វ) |
| | ៣. រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍រៀបចំគោលការណ៍នៃការចូលរួមសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ។ | (គ.ជ.វ.វ) |

**ii) វឌ្ឍនភាពដែលបានតាមដាន**

**សូចនាករ ១៨.១: បន្តរៀបចំសេចក្តីព្រាងច្បាប់អង្គការស្តីពី ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផ្តួចផ្តើមការពិគ្រោះយោបល់ទូលាយជាមួយភាគីពាក់ព័ន្ធ**

ទោះបីជាមានការបញ្ជាក់សារជាថ្មីនូវបំណងរបស់ក្រសួងមហាផ្ទៃដែលជាក្រសួងសម្របសម្រួលក្នុងការបញ្ចប់បង្ហើយសេចក្តីព្រាង "ច្បាប់អង្គការ" ឱ្យបានមុនដំណាច់ឆ្នាំ២០០៦ ក្តី ក៏មន្ត្រីពាក់ព័ន្ធខ្លួនឯងនៅមិនទាន់ដឹងច្បាស់ថាតើនៅពេលណាទើបច្បាប់នេះនឹងត្រូវរៀបចំហើយសម្រាប់ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធឱ្យបានទូលាយមុនពេលដាក់ជូនរដ្ឋសភាជាតិដើម្បីសុំការអនុម័ត។ ការលំបាកដ៏ចម្បងមួយក្នុងការងារនេះទំនងគឺជាការកៀងគរការឯកភាពគ្នានៅក្នុងចំណោមក្រសួងដែលរងផលប៉ះពាល់។ ឆ្លើយតបទៅនឹងសំណួរមួយនៅក្នុងកិច្ចប្រជុំសង្គមស៊ីវិល-រាជរដ្ឋាភិបាលប្រចាំត្រីមាសលើកទីបីដែលមានការជួយសម្របសម្រួលពី NLO កាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧ ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ឯកឧត្តម លេង វី បានឆ្លើយថា "យើង មិនអាចនិយាយបានទេថាពេលណាទើបសេចក្តីព្រាងច្បាប់អង្គការនេះត្រូវបានបញ្ចប់ដោយសារវាអាស្រ័យលើការចូលរួមច្រើនប៉ុណ្ណាដែលយើង [ក្រសួងមហាផ្ទៃ] បានទទួលពីក្រសួងទាំងអស់"។

នៅក្នុងបទបង្ហាញថ្មីៗមួយដែលធ្វើឡើងដោយឯកឧត្តម ព្រំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃនៅក្នុងសិក្ខាសាលាថ្នាក់ជាតិមួយកាលពីថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ មានការលើកឡើងថា "សេចក្តីព្រាងទីមួយនៃច្បាប់អង្គការស្តីពីច្បាប់គ្រប់គ្រងរដ្ឋបាលខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ កំពុងត្រូវបានពិនិត្យដោយក្រសួងមហាផ្ទៃមុនពេលដាក់ជូនការពិគ្រោះយោបល់ទូលាយជាមួយភាគីពាក់ព័ន្ធ"។

នៅក្នុងឱកាសផ្សេងៗគេឃើញមានការចែករំលែកដោយរាជរដ្ឋាភិបាលកម្ពុជានូវពត៌មានខ្លះស្តីពីគ្រោង និងអភិក្រមនៃការតាក់តែងសេចក្តីព្រាងច្បាប់អង្គការនេះ ប៉ុន្តែខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះនៅតែជាអាថ៌កំបាំង។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងនូវការបារម្ភអំពីការអូសបន្លាយមិនឈប់ឈរនៅក្នុងការតាក់តែង និងក្នុងការដាក់សេចក្តីព្រាងច្បាប់អង្គការនេះជូនការពិគ្រោះយោបល់និងការពិនិត្យមើលជាសាធារណៈ។

## សូចនាករ ១៨.២ រៀបចំកម្មវិធីជាតិដោយបញ្ជាក់ពីទម្រង់ការនិងធនធានសម្រាប់អនុវត្តដែលត្រូវចាប់ផ្តើមនៅក្នុងត្រីមាសទី២ ឆ្នាំ ២០០៨

ក្រោយពេលបានផ្សព្វផ្សាយជូនដល់ម្ចាស់ជំនួយនូវសេចក្តីព្រាងក្របខ័ណ្ឌអនុវត្តន៍ដំណាក់កាលត្រៀម [ឆ្នាំ ២០០៦-០៧] នៃការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីខែមិថុនា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញថាខ្លួនចង់ផ្សព្វផ្សាយយុទ្ធសាស្ត្រអនុវត្តន៍នេះនៅក្នុងដំណាក់កាលនេះ។ ក្នុងន័យនេះក្រុមការងារបច្ចេកទេសវិមជ្ឈការនិងវិសហមជ្ឈការដែលដឹកនាំដោយគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមកដល់ពេលនេះបានរៀបចំ ឯកសារយោងការងារសម្រាប់ទីប្រឹក្សាអន្តរជាតិ និងបានតែងតាំងមន្ត្រីរាជរដ្ឋាភិបាលសម្រាប់ឱ្យរៀបចំក្របខ័ណ្ឌ កម្មវិធីសម្រាប់កម្មវិធី អភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលត្រូវចាប់ផ្តើមនៅក្នុង ត្រីមាសទីពីរឆ្នាំ២០០៨។ រាជរដ្ឋាភិបាលកម្ពុជារំពឹងថានឹងដាក់ចេញនូវក្របខ័ណ្ឌនេះឱ្យបានមុនដំណាច់ឆ្នាំ ២០០៧។

នៅក្នុងអំឡុងពេលរាយការណ៍នេះរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តការងារដូចខាងក្រោមនេះ:

- បានអនុម័ត និងបានអនុវត្តកម្មវិធីកសាងសមត្ថភាពឆ្នាំ២០០៧ [បណ្តុះបណ្តាលមន្ត្រីក្រុមប្រឹក្សាឃុំដែលទើបជាប់ឆ្នោត និងមន្ត្រីថ្នាក់ក្រោមជាតិ] សម្រាប់ថ្នាក់ខេត្ត ស្រុក និងឃុំ។
- បានធ្វើបច្ចុប្បន្នភាព និងបានចេញការណែនាំថ្មីនៃផែនការអភិវឌ្ឍន៍ឃុំ [CDP] និង ផែនការវិនិយោគឃុំ [CIP] ។
- បានប្រកាសការបន្តក្រុមការងារគណនេយ្យភាពនៅគ្រប់ខេត្ត-ក្រុងទាំងអស់ និង
- បានប្រកាសការបន្តក្រុមការងារគណនេយ្យភាពនៅគ្រប់ខេត្ត-ក្រុងទាំងអស់ និង
- បានអនុម័តការបង្កើតអនុគណៈកម្មាធិការចំនួន៥ នៃគណៈកម្មាធិការ ជាតិដឹកនាំការងារ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (គ.ជ.វ.វ) ដែលទទួលបន្ទុកផងដែរលើការ ផ្តល់ប្រឹក្សាអំពីការផ្តល់អំណាចតាមវិស័យដែលត្រូវដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់អង្គការនេះ។

សហគមន៍អង្គការមិនមែនរដ្ឋាភិបាលបានបង្ហាញការបារម្ភខ្លាំងអំពីការរៀបចំកម្មវិធី និងការអនុវត្តន៍សកម្មភាពខ្លះនៃសកម្មភាពទាំងឡាយដែលបានលើកឡើងខាងលើមុនពេលបញ្ចប់បង្ហើយសេចក្តីព្រាងច្បាប់អង្គការដោយមានដំណើរការពិគ្រោះយោបល់ជាសាធារណៈឱ្យបានសមស្រប។ ចំពោះអង្គការខ្លះវាគឺជាការបារម្ភដែល

គេចាប់ផ្តើមរៀបចំទម្រង់ការអនុវត្តន៍និងសកម្មភាពនានាដោយមិនមានទិសដៅគោលនយោបាយដែលត្រូវផ្តល់ជូនដោយច្បាប់អង្គការ ។ ប្រការនេះគឺជាលទ្ធផលមួយនៃការអូសបន្លាយការផ្សព្វផ្សាយច្បាប់អង្គការ ។

## សូចនាករ ១៨.៣: រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍រៀបចំគោលការណ៍នៃការចូលរួមសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

ក្រោយការចាប់ផ្តើមគម្រោងគាំទ្រការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅមូលដ្ឋានតាមរយៈវិមជ្ឈការនិងសហវិមជ្ឈការ [PSDD] នៅក្នុងត្រីមាសទីមួយឆ្នាំ២០០៧ គណៈកម្មាធិការ ជាតិដឹកនាំការងារ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ រំពឹងថានឹងផ្សព្វផ្សាយក្របខ័ណ្ឌ កម្មវិធីសម្រាប់កម្មវិធីនេះ ដែលនឹងផ្តល់មូលដ្ឋានសម្រាប់ការជួយគាំទ្រពហុម្ចាស់ជំនួយចំពោះការអនុវត្តន៍វិមជ្ឈការនិងវិសហមជ្ឈការ ។ ដូចបានលើកឡើងខាងលើការរៀបចំឯកសារយោងការងារសម្រាប់អ្នកពិគ្រោះការងារអន្តរជាតិ ដែលត្រូវធ្វើការងារលើក្របខ័ណ្ឌកម្ម-វិធី/ការអនុវត្តន៍ដែលបានលើកឡើងបានបញ្ចប់រួចហើយនៅពេលនេះ ។

### iii) អនុសាសន៍

- អង្គការក្រៅរដ្ឋាភិបាលសូមផ្តល់អនុសាសន៍សូមឱ្យរាជរដ្ឋាភិបាលកម្ពុជាផ្សព្វផ្សាយសេចក្តីព្រាងច្បាប់អង្គការដោយផ្តល់ពេលវេលាសមស្របសម្រាប់ការពិនិត្យជាសាធារណៈមុនពេលសេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ចប់ និងដាក់ជូនរដ្ឋសភាជាតិដើម្បីសុំការអនុម័ត ។ អង្គការមិនមែនរដ្ឋាភិបាលជឿជាក់ថាការពិនិត្យជាសាធារណៈមិនត្រឹមតែរួមចំណែកធ្វើឱ្យច្បាប់នេះមានលក្ខណៈយុត្តិធម៌ និង ប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាបាន និងបង្កើននូវការគាំទ្រនិងភាពជាម្ចាស់សាធារណៈផងដែរ ។
- សហគមន៍អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់អនុសាសន៍ថាការកំណត់ពេលវេលានៃការបញ្ចប់ក្របខ័ណ្ឌអនុវត្តន៍វិមជ្ឈការនិងវិសហមជ្ឈការ គប្បីត្រូវធ្វើបច្ចុប្បន្នភាពដោយសារមានការអូសបន្លាយនៅក្នុងការបញ្ចប់បង្ហើយច្បាប់អង្គការ ។

អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់អនុសាសន៍ថាគោលការណ៍នៃការសំរេចចិត្តនៅថ្នាក់ទាបបំផុត ដែលបញ្ជាក់អះអាងដោយរាជរដ្ឋាភិបាលកម្ពុជាក៏គប្បីគឺជាគោលការណ៍ដឹកនាំលើការងារវិមជ្ឈការផងដែរ ។ ប្រការនេះនឹងធានា បានមិនត្រឹមតែសង្គតិភាពរវាងច្បាប់អង្គការនិងក្របខ័ណ្ឌអនុវត្តន៍ដែលដើរមុនច្បាប់អង្គការដែលកំពុងតាក់តែងនាពេលនេះប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងផ្តល់ផងដែរនូវមូលដ្ឋានមិនលំអៀងនៃការបែងចែកចំណាយនៅក្នុងគ្រប់វិស័យ ។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលក៏ជឿផងដែរ ថាការអនុម័តគោលការណ៍នៃការសំរេចចិត្តនៅថ្នាក់ទាបបំផុតជាគោលការណ៍ដឹកនាំសម្រាប់ការផ្តល់អំណាចតាមវិស័យក៏នឹងលើកស្ទួយផងដែរនូវការចូលរួម និងកិច្ចសហប្រតិបត្តិការពីក្រសួងដែលរងផលប៉ះពាល់ទាំងអស់ផងដែរ ។

# ថវិកាជាតិ និង ហិរញ្ញវត្ថុសាធារណៈ

## i) សូចនាករតាមដានរួម

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវ |
|---|---|---|
| ១៩. បង្កើនជំនឿទុកចិត្តលើថវិការដ្ឋ និងបង្កើនគណនេយ្យភាពក្នុងកិច្ចការហិរញ្ញវត្ថុ | បន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[៤] ដោយ<br>ក- រក្សាឱ្យបាននូវសមិទ្ធផលដែលបានសម្រេចកន្លងមក និងអនុវត្តបញ្ចប់នូវ បណ្តាសកម្មភាពដែលនៅសេសសល់ក្នុងដំណាក់កាលទី១<br>ខ- រៀបចំផែនការសកម្មភាពសម្រាប់ជំហានទី២នៃដំណាក់កាលទី២រួមទាំងផ្តល់អនុសាសន៍សម្រាប់ជាមូលដ្ឋានក្នុងការអនុម័តគំនិតផ្តួចផ្តើមស្តីពីតម្លាភាពក្នុងវិស័យឧស្សាហកម្មរុករក ។<br>គ- បន្តត្រួតពិនិត្យផលប៉ះពាល់នៃការអនុវត្តន៍សូចនាករដែលបានឯកភាពក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

### សេចក្តីផ្តើម

អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍ចំពោះការបញ្ចូលតំណាងម្នាក់របស់អង្គការមិនមែនរដ្ឋាភិបាលទៅក្នុងក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (TWG-PFM) ហើយសង្ឃឹមថានឹងចូលរួមក្នុងលក្ខណៈស្ថាបនាជាមួយសមាជិកទាំងអស់របស់ក្រុមការងារបច្ចេកទេសស្តីពី***លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានពត៌មានទាក់ទងនឹងថវិកា*** និង ***ការរៀបចំថវិកាដែលគាំទ្រជនក្រីក្រ***។ អង្គការមិនមែនរដ្ឋាភិបាលសូមសំដែងនូវការគាំទ្ររបស់ខ្លួនចំពោះផ្នែកអាទិផាពដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល (កសិកម្ម ធារាសាស្ត្រ អភិវឌ្ឍន៍ជនបទ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត អប់រំ សុខាភិបាល អភិបាលកិច្ចល្អ) ហើយរំពឹងថានឹងឃើញនូវការកើនឡើងកាន់តែខ្លាំងឡើងលើវិភាជន៍ថវិកាប្រៀបធៀបទៅនឹងការកើនឡើងនៅក្នុងផ្នែកដែលមិនមែនជាអាទិភាពនៅក្នុងសេចក្តីព្រាងច្បាប់ថវិកាសំរាប់គ្រប់គ្រងឆ្នាំ២០០៨ ខាងមុខ ។

## ii) វឌ្ឍនភាពដែលបានតាមដាន

**19a)** ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាលពីថ្ងៃទី២៧ ខែកក្កដា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្ហាញអំពីភាពរីកចំរើនដែលធ្វើឡើងក្នុងកំឡុងឆមាសទី១នៃឆ្នាំ២០០៧ ព្រមទាំងក្របខ័ណ្ឌមួយសំរាប់ការបញ្ចប់ដំណាក់កាលទី១នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ជាផ្នែកមួយនៃការបញ្ចប់ដំណាក់កាលទី១នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើបច្ចុប្បន្នភាពលើគេហទំព័ររបស់ខ្លួននៅក្នុងខែកញ្ញា ដោយមានបញ្ចូលព្រឹត្តិប័ត្រប្រចាំខែស្ថិតិពេញលេញជាស៊េរីរហូតដល់ខែកក្កដា ឆ្នាំ២០០៧ ដែលរាប់បញ្ចូលនូវការចំណាយប្រចាំខែនៅក្នុងរបាយការណ៍ TOFE[5] ។

[៤] កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

[៥] តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ

**19b)** ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាលពីថ្ងៃទី២៧ ខែកក្កដា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្ហាញនូវប្រកខ័ណ្ឌរបស់ខ្លួនសំរាប់ដំណាក់កាលទី២ និងផែនការសកម្មភាពបន្ថែម។ លើសពីនេះទៀតអង្គការសង្គមស៊ីវិល គាំទ្រចំពោះសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលក្នុងការបង្កើតក្រុមការងារមួយដើម្បីសិក្សាលើគំនិតផ្តួចផ្តើមស្តីពីតម្លាភាពក្នុងវិស័យឧស្សាហកម្មរុះរក (EITI) ដែលត្រូវបានរំពឹងថានឹងធ្វើអនុសាសន៍ទាក់ទងនឹងការអនុម័តនៅត្រឹមពាក់កណ្តាលឆ្នាំ២០០៨ តាមការរំពឹងទុក។

**iii) អនុសាសន៍**

**19a)** ជាផ្នែកមួយនៃការបញ្ចប់ដំណាក់កាលទី១ អង្គការសង្គមស៊ីវិលសុំឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដាក់ ***ផ្សាយការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*** ជាផ្នែកមួយនៃការងាររបស់ខ្លួនឈានទៅសម្រេចបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលយើងចង់បាននៅកម្ពុជា ដែលបានលើកឡើងនៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទំព័រទី៥ (PFMRP p.5) *"របាយការណ៍បច្ចុប្បន្នភាពប្រចាំខែត្រូវបានផ្សព្វផ្សាយជាធារណៈស្តីពីភាពរីកចំរើននៃការអនុវត្តន៍ថវិការាប់បញ្ចូលទាំងការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំផង។"*

# អំពើហិង្សាក្នុងគ្រួសារ និង ការកេងប្រវ័ញ្ច

**i) សូចនាករតាមដានរួម**

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវ |
|---|---|---|
| ២០. អនុម័ត ច្បាប់ និង អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធ ព្រមទាំងអនុវត្តផែនការប្រឆាំងនឹងអំពើហិង្សាគ្រប់ប្រភេទ ព្រមទាំងការជួញដូរ ស្ត្រី និងកុមារស្របតាមបទដ្ឋានអន្តរជាតិ | ១- អនុម័តសេចក្តីព្រាងអនុក្រឹត្យស្តីពីសេចក្តីសំរេចរដ្ឋបាលស្តីពីអំពើហិង្សាក្នុងគ្រួសារ ។ ក្រុមការងារបច្ចេកទេសយេនឌ័រក្រសួងយុត្តិធម៌<br>២-អនុម័តិសេចក្តីព្រាងច្បាប់ស្តីពីលុបបំបាត់ការជួញដូរមនុស្ស និងការជួញដូរ ផ្លូវភេទស្របតាមពិធីសារអង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្សនិងការជួញដូរផ្លូវភេទ និងសន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពីឧក្រិដ្ឋកម្មឆ្លងដែន និងសេចក្តីព្រាងក្រមព្រហ្មទ័ណ្ឌ ។<br>៣. អនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ។ គោលដៅជាក់លាក់សម្រាប់ឆ្នាំ២០០៧នេះគឺការបង្កើតក្រុមការងារនៅក្រសួង មហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋានសម្រាប់រៀបចំឯកសារបណ្តុះបណ្តាលនានា ដើម្បីអនុវត្តអនុក្រឹត្យនេះ ។<br>៤. ពិនិត្យឡើងវិញលើគោលនយោបាយនិងច្បាប់ស្តីពីអន្តោប្រវេសន៍ ។<br>គោលដៅជាក់លាក់សម្រាប់ឆ្នាំ២០០៧រួមមានៈ អនុម័តឯកសារយុទ្ធសាស្ត្រ ស្តីពីអន្តោប្រវេសន៍ ដែលភ្ជាប់ការងារអន្តោប្រវេសន៍ទៅនឹងការជួញដូរ ការរត់ពន្ធ និងកំណែទម្រង់ច្បាប់ការងារព្រមទាំងបំពេញនូវគម្លាតផ្នែកច្បាប់ដែលមានស្រាប់ដើម្បីលើកកំពស់ដល់ការការពារផ្លូវច្បាប់សម្រាប់ជនអន្តោប្រវេសន៍ ។ | ក្រសួងមហាផ្ទៃ<br>ក្រសួងកិច្ចការនារី<br>ក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ |

**ii) វឌ្ឍនភាពដែលបានតាមដាន**

២០.១ អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍ចំពោះកិច្ចប្រឹងប្រែងរបស់ក្រុមការងារអន្តរក្រសួង ( ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី អ្នកជំនាញការ) ក្នុងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីសេចក្តីសំរេចរដ្ឋបាលលើអំពើហឹង្សាក្នុងគ្រួសារ ។ ទោះបីជាយ៉ាងណាក៏ដោយអង្គការមិនមែនរដ្ឋាភិបាលសង្កេតឃើញថា ភាពរីកចំរើនទាក់ទងនឹងការរៀបចំអនុក្រឹត្យស្តីពីសេចក្តីសំរេចរដ្ឋបាលលើអំពើហិង្សាក្នុងគ្រួសារនេះមានភាពយឺតយ៉ាវយ៉ាងខ្លាំង ។ អនុក្រឹត្យដែលបានធ្វើសេចក្តីព្រាងហើយ នៅតែរង់ចាំមតិយោបល់ពីក្រសួងមហាផ្ទៃនៅឡើយ ។

២០.២ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើផ្នែកយេនឌ័រមានការសប្បាយចិត្តចំពោះរាជរដ្ឋាភិបាលដែលបានអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចន៍ផ្លូវភេទកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ។

២០.៣ គេបានប្រើពេលជិតពីរឆ្នាំក្នុងការរៀបចំផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ។ អង្គការមិនមែនរដ្ឋាភិបាលសង្កេតឃើញថាកិច្ចការនិងសកម្មភាពត្រួតគ្នាមួយចំនួនរវាងក្រសួងកិច្ចការនារី

និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតមិនទាន់បានដោះស្រាយបញ្ចប់នៅឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលមានការព្រួយបារម្ភពីការពន្យាពេលក្នុងការបញ្ចប់និងអនុម័តផែនការសកម្មភាពនេះ ។

**iii) អនុសាសន៍**

២០.១ អង្គការមិនមែនរដ្ឋាភិបាលសូមជំរុញឱ្យក្រសួងមហាផ្ទៃពិនិត្យឡើងវិញ និងផ្តល់យោបល់លើអនុក្រឹត្យដែលបានព្រាងរួចហើយដោយគណៈកម្មាធិការអន្តរក្រសួង និងដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យដើម្បីអនុម័តឱ្យបានឆាប់តាមដែលអាចធ្វើបាន ។

២០.២ អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់អនុសាសន៍ឱ្យក្រសួងយុត្តិធម៌ចាត់វិធានការជាបន្ទាន់លើការរៀបចំសេចក្តីថ្លែងបញ្ហាស្តីពីសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ហើយដាក់ជូនរដ្ឋសភាសំរាប់ពិភាក្សា និងអនុម័ត ។

២០.៣ អង្គការមិនមែនរដ្ឋាភិបាលសូមជំរុញឱ្យក្រសួងកិច្ចការនារី ក្រុមការងារបច្ចេកទេសយេនឌ័រ និងស្ថាប័នពាក់ព័ន្ធឱ្យធ្វើការងារឱ្យបានឆាប់ក្នុងការកំណត់តួនាទី និងភារកិច្ចច្បាស់លាស់នៅក្នុងផែនការសកម្មភាពជាតិ ។ មានតំរូវការជាបន្ទាន់ក្នុងការអនុម័តផែនការសកម្មភាពនេះដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលបានអនុម័តរួចហើយអោយបានពេញលេញ ។

# គ្រាប់មីន

## i) សូចនាករតាមដានរួច

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នរាជរដ្ឋាភិបាលដែលទទួលខុសត្រូវ |
|---|---|---|
| ១១. បន្តកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងគ្រាប់មិនទាន់ផ្ទុះចំនួន ៧០-៨០ និងកាត់បន្ថយឱ្យ បាន ៥-១០% នៃដីដែលមានមីននិងគ្រាប់មិនទាន់ផ្ទុះ | ១. អនុវត្តការត្រួតពិនិត្យតាមដាននិងវាយតំលៃអំពីការអនុវត្តន៍សកម្មភាពនានា ដែលបានចែងក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីមីននិងគ្រាប់មិនទាន់ផ្ទុះ ។<br>២. ធានាកាផ្តល់និងការប្រើប្រាស់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ឱ្យបានទាន់ពេលវេលា ។<br>៣. កែលំអយន្តការសម្រាប់ត្រួតពិនិត្យការប្រើប្រាស់ធនធានឱ្យមានតម្លាភាពនិងប្រសិទ្ធភាព ។ | អាជ្ញាធរ សកម្មភាពកំចាត់មីនកម្ពុជា |

## ii) វឌ្ឍនភាពដែលបានតាមដាន

១១.១ (ក) គ្រោះថ្នាក់បណ្តាលមកពីគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះពីខែមករា ដល់ខែសីហា ឆ្នាំ២០០៧ មានចំនួន ២៨១ និង ពីខែមករា ដល់ខែសីហា ឆ្នាំ២០០៦ គឺ៣៥៣។ ចំនួននេះមានការថយចុះចំនួន៧២ករណី។

(ខ) ការបោសសម្អាតមីនសម្រាប់រយៈពេល ៦ ខែ ក្នុងឆ្នាំ ២០០៧ បានដំណើរការយ៉ាងល្អប្រសើរ។ ផ្ទៃដីសរុបដែលបានបោសសម្អាតមីនត្រូវបានកត់ត្រាទុកនៅក្នុងអាជ្ញាធរសកម្មភាពកំចាត់មីនកម្ពុជា។ ផ្ទៃដីដែលត្រូវបានកំណត់ថាមានមីនក៏ត្រូវបានកាត់បន្ថយផងដែរនៅក្នុងរយៈពេល ៦ខែនេះ។

១១.២ ការបញ្ចេញមូលនិធិពីរាជរដ្ឋាភិបាលកម្ពុជា និង មូលនិធិរបស់ដៃគូអភិវឌ្ឍន៍គឺធ្វើបានទាន់ពេល។ ប៉ុន្តែស្ថាប័នបោសសម្អាតមីននៅមិនទាន់បានទទួលការធានាមូលនិធិសម្រាប់ឆ្នាំ ២០០៨ នៅឡើយ។ សម្រាប់គោលបំណងរៀបចំផែនការគេចាំបាច់ត្រូវដោះស្រាយបញ្ហានេះ។

១១.៣ ទម្រង់របាយការណ៍តាមដានដ៏ច្បាស់លាស់មួយធ្វើឱ្យការរាយការណ៍ពីអង្គការ HALO Trust អង្គការ MAG និង CMAC ជូនអាជ្ញាធរសកម្មភាពកំចាត់មីនកម្ពុជាកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។ វាគឺជាយន្តការការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពមួយ។

## iii) អនុសាសន៍

(១១.២) រាជរដ្ឋាភិបាលនិងម្ចាស់ជំនួយគប្បីបញ្ជាក់អះអាងជំនួយមូលនិធិរបស់ខ្លួនសម្រាប់ស្ថាប័នអនុវត្តន៍នានា ដើម្បីឱ្យស្ថាប័នទាំងនេះអាចធ្វើផែនការសកម្មភាពរបស់ខ្លួនជាមុនសម្រាប់ឆ្នាំខាងមុខ។

# ឧបសម្ព័ន្ធ៖ ការវិភាគសូចនាករតាមដានរួមឆ្នាំ២០០៧

ការវិភាគនេះរៀបចំដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល (NGO Forum) ដើម្បីជួយពន្យល់ជូនអង្គការមិនមែនរដ្ឋាភិបាល អំពីសូចនាករតាមដានរួមថ្មីៗមួយចំនួនដែលត្រូវបានឯកភាពគ្នារវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយនៅក្នុងកិច្ចប្រជុំនៃវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) លើកទី១ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ១៩-២០ ខែមិថុនា ឆ្នាំ២០០៧[៦]។ សូចនាករតាមដានរួមទាំងនេះនឹងត្រូវឃ្លាំមើលតាមរយៈក្រុមការងារបច្ចេកទេសរបស់រាជរដ្ឋាភិបាល-ម្ចាស់ជំនួយ និងត្រូវរាយការណ៍ជូនកិច្ចប្រជុំប្រចាំត្រីមាសនៃគណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល-ម្ចាស់ជំនួយ (GDCC)។

កិច្ចប្រជុំ CDCF គឺជាដំណើរការកែសម្រួលដើម្បីឃ្លាំមើលវឌ្ឍនភាពតាមវិស័យ ដែលកាលពីមុនមានឈ្មោះថាក្រុមពិគ្រោះយោបល់ (CG)។ "សូចនាករ" គោលដៅត្រូវបានបែងចែកទៅជាសកម្មភាពដែលរាជរដ្ឋាភិបាល និងម្ចាស់ជំនួយឯកភាពគ្នាថាគប្បីត្រូវសម្រេចឱ្យបានមុនកិច្ចប្រជុំ CDCF បន្ទាប់នាពេលខាងមុខ។ ការសម្រេចបាននូវ សកម្មភាពជាក់លាក់ទាំងនេះត្រូវបានចាត់ទុកថាជាការចង្អុលបង្ហាញដ៏ល្អមួយអំពីវឌ្ឍនភាពនៅក្នុងវិស័យនីមួយៗក្នុងលក្ខណៈជាទូទៅ។

វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាបានស្នើសុំឱ្យក្រុមការងារបច្ចេកទេសនីមួយៗផ្លាស់ប្តូរទៅជាមធ្យោបាយ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសូចនាករតាមដានរួម (JMIs) សម្រាប់កិច្ចប្រជុំ CDCF ឆ្នាំ២០០៧ ដែលនៅក្នុងនោះគេត្រូវរៀបចំសូចនាករយ៉ាងច្រើនតែ៣ ប៉ុណ្ណោះ ដែលត្រូវបានកំណត់ថាមានលក្ខណៈជា "ម៉ាក្រូ យុទ្ធសាស្ត្រ និង គោលនយោបាយ"។ ជាលទ្ធផលសូចនាករចំនួន៥៥ នៃគោលដៅចំនួន ២០ ត្រូវបានឯកភាពគ្នា។ សូចនាករ ឬ សកម្មភាពចាំបាច់ទាំងនេះ ត្រូវបានរៀបចំឡើងស្របតាមអាទិភាពវិស័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ហើយដោយហេតុនេះសូចនាករមានលក្ខណៈស្របតាមគោលដៅនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ សូចនាករត្រូវបានចងក្រងតាមប្រធានបទធំៗចំនួនប្រាំនៃ NSDP ដូចខាងក្រោមនេះ៖

- ការអនុវត្តន៍និងការគ្រប់គ្រង NSDP — ២ គោលដៅ (៥ សូចនាករ/សកម្មភាពចាំបាច់ )
- អាទិភាពវិស័យសង្គមកិច្ចនៃ NSDP — ៤ គោលដៅ (៦ សូចនាករ/សកម្មភាពចាំបាច់)
- អាទិភាពវិស័យសេដ្ឋកិច្ចនៃ NSDP — ៦ គោលដៅ (១៨ សូចនាករ/សកម្មភាពចាំបាច់)
- អាទិភាពវិស័យហេដ្ឋារចនាសម្ព័ន្ធនៃ NSDP — ២ គោលដៅ (៣ សូចនាករ/សកម្មភាពចាំបាច់)
- អាទិភាពវិស័យអភិបាលកិច្ចនិងអន្តរវិស័យនៃ NSDP — ៦ គោលដៅ (២៣ សូចនាករ/សកម្មភាពចាំបាច់)

---

[៦] ឯកសារនេះក៏ផ្អែកផងដែរលើការវិភាគមួយលើសូចនាករតាមដានរួមនៃកិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ ២០០៦ ដែលបានរៀបចំដោយ លោក រ៉ាសែល ភីធ័រសិន (Russell Peterson) នៅក្នុងពេលដែលលោកបំពេញការងារជាទីប្រឹក្សាជាន់ខ្ពស់ជូនអង្គការ NGO Forum នៅក្នុងខែ មីនា ឆ្នាំ ២០០៦។

ក្របខ័ណ្ឌថ្មី និងចំនួនសូចនាករតិចជាងមុននេះមានភាពខុសគ្នាច្រើនពីនិន្នាការមុនដែលនៅក្នុងនោះចំនួនសូចនាករបានកើនឡើងជារៀងរាល់ឆ្នាំៈ សូចនាករចំនួន១០ ត្រូវបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ២០០២ សូចនាករចំនួន៤៥ ត្រូវបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ២០០៤ ហើយសូចនាករចំនួន៦០ ត្រូវបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ឆ្នាំ២០០៦។ ក្របខ័ណ្ឌកែសម្រួលឡើងវិញនៃសូចនាកររបស់វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៏កម្ពុជាឆ្នាំ២០០៧ ក៏ធ្វើឱ្យមានការលំបាកផងដែរក្នុងការប្រៀបធៀបវឌ្ឍនភាពតាមវិស័យទៅនឹងសូចនាករមុនៗដែលត្រូវបានដកចេញ រំកិល និងជាសូចនាករថ្មី។ ប៉ុន្តែតារាងសូចនាករថ្មី[៧] នៅដែលភ្ជាប់ក្នុងឧបសម្ព័ន្ធនៃឯកសារនេះមានបង្ហាញប្រាប់ថាតើសូចនាករណាខ្លះជាសូចនាករថ្មី និងត្រូវបានរំកិលពីសូចនាករឆ្នាំ២០០៦។

**សូចនាករតាមធានរួមថ្មី**

ជាលទ្ធផលនៃលក្ខណៈវិនិច្ឆ័យជ្រើសរើសថ្មីដែលតម្រូវឱ្យសូចនាករមានលក្ខណៈជា ម៉ាក្រូ យុទ្ធសាស្ត្រ និងគោលនយោបាយ សូចនាករថ្មីទាំងនេះផ្តោតលើការអនុវត្តន៏តិចជាងសូចនាករមុន និងយកចិត្តទុកដាក់ខ្លាំងទៅលើការជម្រុញកិច្ចអភិវឌ្ឍន៏ផ្នែកឯកជន។

ពាក់ព័ន្ធនឹងបញ្ហាដីធ្លី និងអភិបាលកិច្ចធនធានធម្មជាតិ គេឃើញមានសូចនាករសំខាន់ៗថ្មីមួយចំនួនដែលគប្បីពិនិត្យមើល។ សូចនាករ ៨.១ "*អនុម័តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការចុះបញ្ជីនិងសិទ្ធិប្រើប្រាស់ដីសហគមន៏ជនជាតិដើមភាគតិច និងចាត់វិធានការការពារបឋមដើម្បីការពារដីរបស់សហគមន៏ជនជាតិដើមភាគតិចទាំងនេះនៅក្នុងខេត្តចំនួន២*" បង្ហាញនូវការផ្លាស់ប្តូរគោលនយោបាយពីសូចនាករមុនដែលវាស់គោលនយោបាយ និង បទប្បញ្ញត្តិទូលាយរបស់រាជរដ្ឋាភិបាលចំពោះជនជាតិដើមភាគតិចទៅជាការយកចិត្តទុកដាក់លើគោលនយោបាយស្តីពីការចុះបញ្ជីនិងសិទ្ធិប្រើប្រាស់។ ចំណុចនេះធ្វើឱ្យក្រុមសង្គមស៊ីវិលមានាករបារម្ភដោយសារគោលនយោបាយនេះមិនត្រឹមតែធ្វើឱ្យខូចខាតដល់សិទ្ធិនិងបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ប៉ុណ្ណោះទេ វាថែមទាំងឈប់ផ្តោតអន្តរាគមន៏លើការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៏ដែលជាអាទិភាពមួយនៅក្នុង NSDP ទៀតផង។ សូចនាករ ៩.១ "*អនុវត្តបញ្ញត្តិទាំងអស់នៃអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ចដែលរួមមានការរៀបចំសៀវភៅកត់ត្រាអំពីដីសម្បទានសេដ្ឋកិច្ចសម្រាប់ផ្សព្វផ្សាយជាសាធារណៈ រួមមានដីសម្បទានសេដ្ឋកិច្ចដែលបានសម្រេចនៅថ្នាក់ខេត្ត និងការពិនិត្យឡើងវិញលើការផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលមានទំហំធំជាង ១០.០០០ហ.ត ចំនួនយ៉ាងតិច៥កន្លែង ការចាត់វិធានការសមស្របដោយអនុលោមតាមជំពូកទី៦នៃអនុក្រិត្យស្តីពីដីសម្បទានសេដ្ឋកិច្ច*" ទាក់ទងគ្នានឹងសូចនាករ៨.២មុន ប៉ុន្តែទទួលស្គាល់ថាមកដល់ពេលនេះ ដីសម្បទានចំនួនកាន់តែច្រើនឡើងត្រូវបានផ្តល់នៅថ្នាក់ខេត្តដោយមិនមានការផ្សព្វផ្សាយពតិមានជាសាធារណៈឡើយ (ដូច្នេះគឺផ្ទុយទៅនឹងបញ្ញត្តិនានានៃអនុសក្រិត្យស្តីពីដីសម្បទានសេដ្ឋកិច្ច)។ សូចនាករ១០.១, ១០.២ និង ១០.៣ "សកម្មភាព

[៧] សូមរកមើលនៅលើគេហទំព័ររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល

សមស្របដើម្បី ឆ្លុះបញ្ចាំងអាទិភាពទាំងឡាយនៃវិស័យជលផលដើម្បីកែលម្អជីវភាពរស់នៅរបស់សហគមន៍ជនបទនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ស្រុក និង ខេត្ត ក៏ដូចជាកម្រិតផ្តល់មូលនិធិរបស់ម្ចាស់ជំនួយផងដែរ" ផ្តោតលើការតាក់តែងក្រមប្រតិបត្តិសម្រាប់ការងារជលផលប្រកបដោយការទទួលខុសត្រូវ និងពង្រឹងការជួយឧបត្ថម្ភផ្នែកហេដ្ឋារចនាសម្ព័ន្ធជូនដល់រដ្ឋបាលជលផល។

វាគឺជាប្រការគួរឱ្យខកចិត្តដែលពុំមានសូចនាករទាក់ទិននឹងដីធ្លីណាមួយដែលព្រៀងឡើងនៅក្នុងដំណើរការពិគ្រោះយោបល់អង្គការមិនមែនរដ្ឋាភិបាលកាលពីខែមេសា និងឧសភា ឆ្នាំ២០០៧ ត្រូវបានដាក់បញ្ចូលនៅក្នុងសូចនាករចុងក្រោយដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំ CDCF ឆ្នាំ២០០៧ឡើយ។

**សូចនាករដែលត្រូវបានរំកិល**

យោងតាមវឌ្ឍនភាពដែលបានរាយការណ៍នៅក្នុងរបាយការណ៍ស្តីពីវឌ្ឍនភាពសូចនាករនៃកិច្ចប្រជុំពិគ្រោះយោបល់ (CG) ឆ្នាំ២០០៦[៨] សូចនាករចំនួន២១ នៃសូចនាករសរុបចំនួន៦០មិនត្រូវបានសម្រេចយ៉ាងពេញលេញឡើយ។ នៅក្នុងចំណោមសូចនាករទាំង២១នេះ សូចនាករចំនួន១៤ត្រូវបានរំកិលទៅក្នុងសូចនាករថ្មីឆ្នាំ២០០៧ ដោយសារវាមិនទាន់បានសម្រេច។ ចំណុចនេះរួមមានច្បាប់ប្រឆាំងអំពើពុករលួយដែលត្រូវបានដាក់បញ្ចូលក្រោយការបញ្ចុះបញ្ចូល (lobby) ដ៏ខ្លាំងពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលនិងម្ចាស់ជំនួយនៅក្នុងកិច្ចប្រជុំ GDCC នៅក្នុងខែឧសភា ឆ្នាំ២០០៧ និងការបញ្ចប់និងអនុម័តច្បាប់សំខាន់៧ដែលនៅសេសសល់។ លើសពីនេះទៀតមានចំណុចមិនច្បាស់លាស់ថា ហេតុអ្វីបានជាសូចនាករថ្មីចំនួនបួនត្រូវបានដាក់បញ្ចូលខណៈដែលរបាយការណ៍វឌ្ឍនភាពសូចនាករ (ឆ្នាំ ២០០៦) លើកឡើងថាសូចនាករ ទាំងនេះបានសម្រេចរួចហើយ។ សូចនាករទាំងនេះរួមមានសូចនាករ ៨.២ ស្តីពីដីសម្បទានសេដ្ឋកិច្ច (សូចនាករ២០០៦: ៨.៤) JMI ៩.២ ស្តីពីការកំណត់ព្រំដែនព្រៃឈើ (សូចនាករ២០០៦: ១១.ខ) សូចនាករ ១៥.៣ ស្តីពីរដ្ឋបាលសាធារណៈ (សូចនាករ២០០៦: ៥.៤)។

**សូចនាករដែលមិនត្រូវបានដាក់បញ្ចូល ឬដែលត្រូវបានដកចេញ**

គេមិនដឹងច្បាស់ទេថាហេតុអ្វីបានជាសូចនាករនៅសល់ទាំង១១ ដែលមិនបានសម្រេចមិនត្រូវបានរំកិលទៅក្នុងការជ្រើសរើសសូចនាករថ្មី ទោះបីជាមានការព្រមព្រៀងគ្នាថាសូចនាករដែលបានឯកភាពគ្នានៅក្នុងឆ្នាំ២០០៥ ប៉ុន្តែមិនទាន់បានសម្រេចគប្បីត្រូវរំកិលទៅក្នុងឆ្នាំបន្ទាប់ក្តី។ គេក៏មិនដឹងច្បាស់ដែរថាតើសូចនាករមុនទាំងនេះនឹងបន្តនៅជាបញ្ហាជាអាទិភាពឬទេសម្រាប់ក្រុមការងារបច្ចេកទេសពាក់ព័ន្ធ។

សូចនាករនៅក្នុងវិស័យដីធ្លីនិងធនធានធម្មជាតិដែលត្រូវបានដាក់បញ្ចូលកាលពីពេលមុន (ហើយសូចនាករទាំងនេះត្រូវបានសម្រេច) ពុំត្រូវបានដាក់បញ្ចូលជាបន្តទៀតនៅក្នុងសូចនាករថ្មីឆ្នាំ២០០៧ទេ បើទោះបីជាបញ្ហាទាមទារអោយមានជាបន្តក៏ដោយ។ ចំណុចនេះរួមមានការចុះបញ្ជីដីធ្លី (ការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ យន្តការ

---

[៨] រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០៧ "ការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា: របាយការណ៍ស្តីពីវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅនៃសូចនាករតាមដានរួមដែលបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ដែលប្រព្រឹត្តទៅក្នុង ខែ មីនា ឆ្នាំ ២០០៦" ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ខែ កុម្ភៈ ឆ្នាំ ២០០៧។

ដោះស្រាយវិវាទដីធ្លី ដំណើរការគណៈកម្មការសុរិយោដី និង ការកំណត់ផែនទីដីរដ្ឋ) ការអនុវត្តន៍កម្មវិធីព្រៃឈើថ្នាក់ជាតិ (ការពង្រឹងប្រតិបត្តិច្បាប់ស្តីពីព្រៃឈើ ការអនុវត្តន៍កម្មវិធីព្រៃឈើសហគមន៍ និង ការឃ្លាំមើលវិស័យព្រៃឈើដោយឯករាជ្យ) ។

លើសពីនេះទៅទៀតមានសូចនាករមួយចំនួនដែលមិនទាន់បានសម្រេចនៅឡើយប៉ុន្តែត្រូវបានដកចេញរួមមាន:

- សូចនាករចាស់ ៤.៣ "កំណត់ពេលវេលាដើម្បីបញ្ចប់ច្បាប់និងបទប្បញ្ញត្តិទាំងឡាយដែលចាំបាច់ដើម្បីបំពេញតាមលក្ខខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និង អនុវត្តភារកិច្ចទាំងឡាយតាមពេលវេលាកំណត់ នោះ" ។
- សូចនាករចាស់ ៤.៥.ង "អនុម័តយុទ្ធសាស្ត្រនិងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលសម្រាប់ជនជាតិដើមភាគ តិច"
- សូចនាករចាស ៨.៥ "រៀបចំគោលនយោបាយប្រព័ន្ធសុវត្ថិភាពសង្គមដើម្បីធានាឱ្យបាននូវសន្តិសុខស្បៀង និង អាហារូបត្ថម្ភសម្រាប់ក្រុមប្រជាជនងាយរងគ្រោះជាងគេបំផុត"
- សូចនាករចាស ៨.៦ "រៀបចំប្រព័ន្ធតាមដានអាហារូបត្ថម្ភដើម្បីឃ្លាំមើលសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ"
- សូចនាករចាស ៩.៤ "ដាក់ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកនិងអនាម័យជូនទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យសម្រេច"
- សូចនាករចាស ៩.៥ "រៀបចំសេចក្តីព្រាងស្ថិតិថាមពលខុស និង គោលនយោបាយថាមពលខុសកម្ពុជា"
- សូចនាករចាស ១២.២.ក "ពង្រឹងការសម្រួលពាណិជ្ជកម្ម អនុមតិ និង ប្រើប្រាស់ឯកសាររដ្ឋបាលតែមួយ (SAD) តាមប្រព័ន្ធអាស៊ីគូដា Asycuda"
- សូចនាករចាស ១២.២.ខ "ពង្រឹងការសម្រួលពាណិជ្ជកម្ម អនុមតិ និង បោះផ្សាយកិច្ចព្រមព្រៀងរដ្ឋបាលអន្តរស្ថាប័ននៅក្នុងចំណោមស្ថាប័នពាក់ព័ន្ធទាំងអស់ស្តីពីនីតិវិធីនិងការណែនាំសម្រាប់ការធ្វើអធិការកិច្ច និង ការបញ្ចេញទំនិញនាំចូលនិងទំនិញនាំចេញ"
- សូចនាករចាស ១២.២.គ "ពង្រឹងការសម្រួលពាណិជ្ជកម្ម: ដាក់ឱ្យអនុវត្តសាកល្បងច្រកចេញចូលតែមួយ (SW) សម្រាប់ការសម្រួលពាណិជ្ជកម្មនៅក្នុងអាជ្ញាធរកំពង់ផែក្រុងព្រះសីហនុ (PAS)"
- សូចនាករចាស ១២.២.ឃ "ពង្រឹងការសម្រួលពាណិជ្ជកម្ម តាក់តែង និង អនុមតិអនុក្រិត្យស្តីពីការសម្រួលពាណិជ្ជកម្មតាមរយៈអភិក្រមគ្រប់គ្រងហានិភ័យចំពោះការធ្វើអធិការកិច្ចនិងការបញ្ចេញទំនិញនាំចូលនិងនាំចេញ ដោយកំណត់ទីចាត់ការគយនិងរដ្ឋាករជាស្ថាប័ននាំមុខសម្រាប់ការធ្វើអធិការកិច្ចគ្រប់ប្រភេទ (អធិការកិច្ចឯកសារ រូបវ័ន្ត និង អេឡិកត្រូនិក)"

**ការវាយតម្លៃរួម**

ការមិនដាក់បញ្ចូលសូចនាករដែលបានលើកឡើងខាងលើដែលមិនទាន់សម្រេចបាននៅឡើយ ឬក៏សម្រេចបានតែមួយផ្នែកប៉ុន្តែត្រូវបានដកចេញនៅពេលនេះគឺជាការគួរឱ្យស្តាយ ដោយសារសូចនាករការទាំងនេះត្រូវបានចាត់ទុកជាបញ្ហាអាទិភាពកាលពីពេលមុន និង ត្រូវបានដាក់បញ្ចូលក្រោយមានការគាំទ្រដ៏ខ្លាំងក្លាពីក្រុមសង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍នៅ ក្នុងកិច្ចប្រជុំមុនៗរបស់គណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល-ម្ចាស់ជំនួយ និង ក្រុមពិគ្រោះយោបល់។ ប្រការគួរឱ្យបារម្ភបំផុតគឺការងាកចេញពីសូចនាករវឌ្ឍនភាពដែលអាចវាស់បានឆ្លុះបញ្ចាំងអទិភាពទូលំទូលាយតាមវិស័យទៅកាន់សូចនាករគោលនយោបាយនិងយុទ្ធសាស្ត្រវិញដែលវឌ្ឍនភាពរបស់វាមានលក្ខណៈលំបាកជាងក្នុងការវាយតម្លៃ។ ចំពោះវិស័យដីធ្លីនិងធនធានធម្មជាតិ ចំណុចជាអាទិភាពគន្លឹះនានាដែលមិនត្រូវបានដាក់បញ្ចូល ជាបន្តទៅទៀតរួមមានការផ្សព្វផ្សាយពត៌មានសាធារណៈប្រកបដោយតម្លាភាព ប្រសិទ្ធ-ភាពនៃយន្តការចុះបញ្ជីដីធ្លី និងគំនិតផ្តួចផ្តើមសម្រាប់ជនជាតិដើមភាគតិចដែលមិនផ្អែកលើសិទ្ធិរបស់ពួកគេដូចដែលមានចែងនៅក្នុង ក្របខ័ណ្ឌគតិយុត្តិកម្ពុជា។

ទោះជាយ៉ាងណាក្តីក៏សូចនាករ
ថ្មីផ្តល់នូវឱកាសមួយសម្រាប់ឃ្លាំមើលវឌ្ឍនភាពរបស់ប្រទេសកម្ពុជានៅក្នុងវិស័យថ្មីៗមួយចំនួន
ហើយអង្គការមិនមែនរដ្ឋាភិបាលគប្បីត្រៀមខ្លួនជាស្រេចដើម្បីជួយដល់ការឃ្លាំមើលនេះ។ អង្គការមិនមែនរដ្ឋាភិបាលក៏គប្បីត្រៀមលក្ខណៈផងដែរដើម្បីលើកឡើងនូវបញ្ហាណាទាំងឡាយណាដែលពួកគេយល់
ថាមានសារសំខាន់ និងដែលអាចមានសារសំខាន់ដើម្បីដាក់បញ្ចូលនៅក្នុងការតាមដានរួមរវាងរាជរដ្ឋាភិបាលនិងម្ចាស់ជំនួយនៅក្នុងបណ្តាឆ្នាំខាងមុខ។